ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

# គោលការណ៍ណែនាំសម្រាប់អ្នកសម្របសម្រួល ស្តីពី សាលារៀនស្រែកសិករ






**រៀបចំដោយ :** កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

**ឧបត្ថម្ភដោយៈ** រាជរដ្ឋាភិបាលកម្ពុជា និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម (IFAD)

IFAD
Investing in rural people

ភ្នំពេញ ខែ កក្កដា ឆ្នាំ ២០១៧

# មាតិកា


**អារម្ភកថា....................................................................4**
**សេចក្តីផ្តើម ....................................................................5**
**ជំពូកទី ១ ....................................................................7**
**គោលគំនិត លក្ខណៈ និងគោលការណ៍សាលារៀនស្រែកសិករ ....................................................................7**
**១. ប្រវត្តិសាលារៀនស្រែកសិករ ....................................................................7**
**២.គោលគំនិត និងទស្សនៈទានសាលារៀនស្រែកសិករ ....................................................................7**
២.១. និយមន័យសាលារៀនស្រែកសិករ.................................................................... 7
២.២. គោលបំណងសាលារៀនស្រែកសិករ .................................................................... 8
**៣. គោលការណ៍សាលារៀនស្រែកសិករ....................................................................9**
**៤. លក្ខណៈសាលារៀនស្រែកសិករ ....................................................................11**
**ជំពូកទី ២ ការរៀបចំ និងដំណើរការសាលារៀនស្រែកសិករ....................................................................14**
១.១. ការបណ្តុះបណ្តាលគ្រូបង្គោល .................................................................... 14
១.២. ការកំណត់ប្រធានបទ ទីកន្លែង និងកសិករចូលរួម .................................................................... 15
១.៣. ការរៀបចំធ្វើស្រែបង្ហាញ .................................................................... 16
១.៤. ការរៀបចំដំណើរការវគ្គសាលារៀនស្រែកសិករមួយ .................................................................... 29
១.៥. បិទវគ្គ និងធ្វើទិវាស្រែ.................................................................... 31
១.៦. ការដំណើរការសាលារៀនស្រែកសិករដោយកសិករគំរូ.................................................................... 32
១.៧. ការតាមដានបន្តរបស់អ្នកសម្របសម្រួល.................................................................... 32
**ជំពូកទី ៣ គោលគំនិត វិធីសាស្រ្ត និងឧបករណ៍សំខាន់ៗប្រើប្រាស់ និងវិធីសាស្រ្តសម្របសម្រួល ក្នុងសាលារៀនស្រែកសិករ....................................................................33**
**១. គោលគំនិត វិធីសាស្រ្ត និងឧបករណ៍សំខាន់ៗប្រើប្រាស់ ក្នុងសាលារៀន ស្រែកសិករ ....................................................................33**
១.១. ប្រព័ន្ធអេកូឡូស៊ី (ប្រព័ន្ធបរិស្ថាន) .................................................................... 33
១. ២. ទស្សនៈនេះជាអ្វី? នោះជាអ្វី?.................................................................... 34
១. ៣. ការវិភាគក្សេត្រ-បរិស្ថាន .................................................................... 36
**២. វិធីសាស្រ្តសម្របសម្រួល ក្នុងសាលារៀនស្រែកសិករ ....................................................................39**
២.១. ការផ្តល់មេរៀន និងការបកស្រាយបង្ហាញ .................................................................... 39
២.២. ការធ្វើបង្ហាញជាក់ស្តែង .................................................................... 40

២.៣. ការពិភាក្សាក្រុមតូច ........................................ 41
២.៤. ការពិភាក្សាក្រុមធំ ឬពិភាក្សារួម ........................................ 42
២.៥. ការបំផុសគំនិត ........................................ 42
២.៦. ការចុះពិនិត្យ និងសង្កេតផ្ទាល់ ........................................ 43
២.៧. ការលើកករណីសិក្សា ........................................ 44
២.៨. ការរៀបចំការសំដែងតួ ឬ សំដែងសកម្មភាព (Role Play) ........................................ 45
២.៩. ល្បែងស្ថាបនាក្រុម (Team Building Exercise) ........................................ 46
២.១០. ការបង្កើតល្បែងកំសាន្ត (Ice Breaker) ........................................ 46
២.១១. ការសន្ទនា និងជជែក ........................................ 47
២.១២. សំណួរ និងចម្លើយ ........................................ 47
២.១៣. ការផ្តល់មេរៀនពិសេសខ្លីៗ ........................................ 49
២.១៤. ការប្រើឯកសារសោតទស្សន៍ ឬប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គម ........................................ 49
**ជំពូកទី ៤ ការរៀបចំប្លង់មេរៀនក្នុងសាលារៀនស្រែកសិករមួយ ........................................ 51**
១. ការរៀបចំប្លង់មេរៀនសម្រាប់សាលារៀនស្រែកសិករ ........................................ 51
២. គំរូប្លង់ការរៀបចំការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ........................................ 52
៣. គំរូសកម្មភាពសាលារៀនស្រែកសិករក្នុងសប្តាហ៍នីមួយៗ ........................................ 54
៣.១. សប្តាហ៍ទី១ : ការបើកវគ្គជាផ្លូវការ និងណែនាំពីសាលារៀនស្រែកសិករ ........................................ 54
៣.២. សប្តាហ៍ទី២: ទៅសប្តាហ៍បន្តបន្ទាប់ ........................................ 56
៣.៣. សប្តាហ៍ទី ...... ការគ្រប់គ្រងអាជីវកម្មកសិកម្ម និងទីផ្សារ ........................................ 56
៣.៤. សប្តាហ៍ទី.......ការវិភាគចំណូល ចំណាយក្នុងរបរអាជីវកម្មកសិកម្ម ........................................ 60
៣.៥. សប្តាហ៍ទី.......ការយល់ដឹងអំពីដំណើរការទីផ្សារ និងទីផ្សារ ........................................ 23
៣.៦. សប្តាហ៍ទី.......ការរៀបចំគម្រោងអាជីវកម្មកសិកម្មមួយក្នុងកសិដ្ឋាន ........................................ 27
**ជំពូកទី ៥ ការពិនិត្យតាមដាន និងវាយតម្លៃ និងកត់ត្រាសាលារៀនស្រែកសិករ ........................................ 33**
**ឯកសារយោង ........................................ 38**

# អារម្ភកថា

អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំគោលការណ៍ណែនាំពីសាលារៀនស្រែកសិករ សម្រាប់ប្រើប្រាស់ក្នុងការបណ្តុះបណ្តាលអ្នកសម្របសម្រួលក្នុងសាលារៀនស្រែកសិករនិងការផ្សព្វផ្សាយ បច្ចេកវិទ្យា បច្ចេកទេស និងការអនុវត្តល្អថ្មីៗ ពាក់ព័ន្ធនឹងកសិកម្មដែលធន់ នឹងការប្រែប្រួលអាកាសធាតុ ធ្វើមុខរបរអាជីវកម្ម កសិកម្ម ការចាត់ចែង និងគ្រប់គ្រងក្រុមកសិករ និងដើម្បីលើកកម្ពស់ ផលិតភាព គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម និងបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ គោលការណ៍ណែនាំ នេះក៏អាចប្រើប្រាស់បានសម្រាប់បណ្តុះបណ្តាលគ្រូបង្គោលផ្សព្វផ្សាយ អ្នកបច្ចេកទេស កសិកម្ម និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មឃុំ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មនានានៅមូលដ្ឋាន។

គោលការណ៍ណែនាំនេះរៀបចំឡើង ក្នុងក្របខ័ណ្ឌឯកសារបណ្តុះបណ្តាល និងផ្សព្វផ្សាយដោយមានការចូលរួមសម្រាប់អនុវត្តការផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យា ដល់កសិករ និងប្រតិបត្តិករនានាដែលពាក់ព័ន្ធនឹងកម្មវិធី ផ្សព្វផ្សាយកសិកម្មនានាក្នុងបរិបទតម្រូវការទីផ្សារ និងការប្រែប្រួលអាកាសធាតុ។ គោលការណ៍ណែនាំនេះបានរៀបចំ ឡើងដោយផ្អែកលើបទពិសោធន៍នានាពីសាលារៀនស្រែកសិករនានានៅកម្ពុជា មានសាលារៀនស្រែកសិករពីវិធានការណ៍ចម្រុះថែទាំដំណាំលើស្រូវ បន្លែ សាលារៀនស្រែកសិករពីវិធាន-ការណ៍ចម្រុះគ្រប់គ្រងដីជាតិដី និងការអភិវឌ្ឍបច្ចេកទេសដោយមានការចូលរួមនានារបស់កម្មវិធីផ្សព្វផ្សាយ កសិកម្មនៅតាមបណ្តាភូមិឃុំនានានៅកម្ពុជា។

គោលការណ៍ណែនាំនេះធ្វើឡើង ដោយធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយអ្នកផ្សព្វផ្សាយកសិកម្ម អ្នកជំនាញ បច្ចេកទេស អ្នកឯកទេស និងអ្នកពាក់ព័ន្ធមកពីស្ថាប័ន និងអង្គភាពផ្សព្វផ្សាយកសិកម្ម អង្គភាពជំនាញបច្ចេកទេសនានា ។

គោលការណ៍ណែនាំនេះ ជាឯកសារគ្រឹះដែលពិពណ៌នាពីបច្ចេកទេស វិធីសាស្ត្រ និងនិតិវិធីរៀបចំ និងសម្របសម្រួលក្នុងសាលារៀនស្រែកសិករ ដើម្បីជួយដល់មន្ត្រីផ្សព្វផ្សាយ មន្ត្រីបច្ចេកទេស មន្ត្រីផ្សព្វផ្សាយកសិកម្ម ស្រុកនិងភ្នាក់ងារផ្សព្វផ្សាយនៅមូលដ្ឋាននានា យកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាលនិងផ្សព្វផ្សាយ បច្ចេកទេស ដើម្បីផ្ទេរចំណេះដឹង ព័ត៌មាននិងបច្ចេកវិទ្យាកសិកម្មដល់ប្រជាកសិករនិងប្រតិបត្តិករក្នុងកម្មវិធីផ្សព្វផ្សាយកសិកម្ម និងកម្មវិធីនិងគម្រោងអភិវឌ្ឍកសិកម្មនានានៅកម្ពុជា។

អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ សូមដាក់ចេញនូវគោលការណ៍ណែនាំពីសាលារៀនស្រែកសិករនេះ ដែលជាឯកសារគ្រឹះសម្រាប់មន្ត្រីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-រាជធានី ក្រុង ស្រុក ខណ្ឌ អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទ។

**រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧**

**អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម**

# សេចក្តីផ្តើម

ការប្រែប្រួលអាកាសធាតុជាបញ្ហាសាកល ដែលកើតមានឡើងយ៉ាងច្បាស់ និងមានឥទ្ធិពលលើវិស័យកសិកម្ម ធនធានទឹក ជាពិសេសផលិតកម្មស្បៀងអាហារនៅក្នុងបណ្តាប្រទេសមួយចំនួនលើសាកលលោក ដោយការកើនឡើងកំដៅ គ្រោះទឹកជំនន់ រាំងស្ងួត ភ្លៀងមិនទៀងទាត់ ការកើនឡើងកម្ពស់ទឹកសមុទ្រហូរនិងជ្រាបចូលដីស្រែ ចំការការផ្ទុះនូវសត្វល្អិត ជម្ងឺ ។ល។ ព្រះរាជាណាចក្រកម្ពុជាបានទទួលរងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុរួចមកហើយ ដោយមានការកើតឡើង ពីភាពមិនប្រក្រតីនៃអាកាសធាតុ ដូចជា មានព្រឹត្តិការណ៍ទឹកជំនន់ ភាពរាំងស្ងួត សត្វល្អិត និងជម្ងឺបំផ្លាញ ខ្យល់ព្យុះ ការកើនឡើងកម្ពស់ទឹកសមុទ្រ ដែលបណ្តាលឲ្យមាន ផលិតភាពកសិកម្មទាប និងមានផលប៉ះពាល់ដល់សន្តិសុខស្បៀង និងភាពក្រីក្រ។ ប្រទេសកម្ពុជាមានឆ្នេរសមុទ្រវែងរហូតដល់ ៤៣៥គីឡូម៉ែត្រ និងមានរយៈកម្ពស់ទាប ផ្ទៃដីវាលទំនាប តាមអាងទន្លេគង្គក្រោម តំបន់ទន្លេសាប ហើយមានប្រជាពលរដ្ឋរស់នៅច្រើន និងមានសកម្មភាពសេដ្ឋកិច្ចពឹងផ្អែកលើមុខរបរកសិកម្ម ធនធានជលផល ព្រៃឈើ និងធនធានធម្មជាតិ ហើយមានផ្ទៃដីស្រែទំនាបពឹងដោយរបបទឹកភ្លៀង ប្រមាណជាង ២.៥លានហិកតា។

វិស័យកសិកម្មបានទទួលរងពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ តែវិស័យកសិកម្មក៏បានចូលរួមចំណែក យ៉ាងសំខាន់ក្នុងការបន្សាំ បង្កើនភាពធន់ និងបន្ធូរបន្ថយផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ ដើម្បីធានាប្រព័ន្ធផលិត ចែកចាយ និងផ្គត់ផ្គង់ស្បៀង មាននិរន្តរភាពសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភតាមរយៈការប្រើប្រាស់ បច្ចេកវិទ្យា បច្ចេកទេសនិងការអនុវត្តកសិកម្មល្អនានាដូចជា ពូជដំណាំធន់ ពូជសត្វ ការអនុវត្តប្រព័ន្ធកសិកម្មចម្រុះ ប្រពលវប្បកម្មដំណាំ សត្វ ច្បារដំណាំគ្រួសារ កសិកម្មអភិរក្ស ប្រព័ន្ធដំណាំស្បៀង និងថាមពលចម្រុះ ប្រព័ន្ធគ្រប់គ្រងព្រៃឈើ ដី និងទឹកមាននិរន្តរភាព និងកសិរុក្ខកម្ម។ល។

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE) ជាកម្មវិធីជាតិមួយមានគោលបំណងកាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់របស់គ្រួសារកសិករក្រីក្រនិងងាយរងគ្រោះខ្នាតតូចនៅកម្ពុជា។ កម្មវិធីនេះមានគោលដៅ កែលំអសេវាផ្សព្វផ្សាយកសិកម្មដល់កសិករខ្នាតតូចនៅកម្ពុជា និងទទួលបានការលើកកម្ពស់គំរូមួយសម្រាប់សេវាកសិកម្ម ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច តាមរយៈបង្កើនប្រាក់ចំណូល និងភាពធន់នឹងអាកាសធាតុក្នុងមុខរបរកសិកម្ម។

គោលការណ៍ណែនាំសម្រាប់សម្របសម្រួលសាលារៀនស្រែកសិករនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់គោលការណ៍ណែនាំដល់មន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ឱ្យមានសមត្ថភាពសម្រាប់ ដឹកនាំការពិភាក្សា និងសម្របសម្រួលក្នុងការចងក្រុមកសិករសិក្សា ការវាយតម្លៃតម្រូវការរបស់កសិករ និងដំណើរការសាលារៀនស្រែកសិករលើអនុវត្តបច្ចេកទេសកសិកម្មថ្មី ការធ្វើមុខរបរអាជីវកម្មកសិកម្ម និងការលើកកម្ពស់ការចាត់ចែង និងគ្រប់គ្រងក្រុមកសិករ ដើម្បីលើកកម្ពស់ផលិតភាព គុណភាព

និងសុវត្ថិភាពផលិតផលកសិកម្ម បង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុនិងបង្កើនប្រាក់ចំណូលគ្រួសារ។

តាមរយៈឧបករណ៍ វិធីសាស្ត្រ និងលំហាត់នានានៃឯកសារណែនាំនេះ ដូចជាការពិព័ណ៌នា និងពិភាក្សា ពីការរៀបចំក្រុមកសិករសិក្សា វិភាគបញ្ហាការប្រែប្រួលអាកាសធាតុ និងការអនុវត្តបច្ចេកវិទ្យា ការអនុវត្តបច្ចេកទេស ការអនុវត្តនូវនវានុវត្តន៍ថ្មីៗ និងការគ្រប់គ្រងរបរអាជីវកម្មកសិកម្ម ប្រធានបទនៃការប្រែប្រួលអាកាសធាតុ ជាពិសេសផលប៉ះពាល់និងសកម្មភាពនានាដែលកសិករអាច អនុវត្តដើម្បីបន្ថយភាពងាយរងគ្រោះ និងបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិនានា។

អគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ជាអ្នកផ្តល់ការបណ្តុះបណ្តាលក្នុងការប្រើប្រាស់គោលការណ៍ណែនាំនេះដល់អ្នកផ្សព្វផ្សាយកសិកម្មនានារួមមាន មន្ត្រីផ្សព្វផ្សាយកសិកម្មរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មនៅមូលដ្ឋាននានា និងជាអ្នកត្រួតពិនិត្យ និងវាយតម្លៃគុណភាពដំណើរសាលារៀនស្រែកសិករ និងស្រែបង្ហាញ ហើយធ្វើការវិភាគ និងវាយតម្លៃពីដំណើរការអនុវត្តសៀវភៅណែនាំនេះ។

### តើអ្នកណាប្រើប្រាស់ឯកសារគោលការណ៍ណែនាំនេះ?

គោលការណ៍ណែនាំនេះអាចប្រើប្រាស់បានដោយមន្ត្រីបច្ចេកទេស មន្ត្រីផ្សព្វផ្សាយ ភ្នាក់ងារប្រតិបត្តិ និងអ្នកផ្សព្វផ្សាយនៅមូលដ្ឋាន សម្រាប់ដឹកនាំ សម្របសម្រួលក្នុងសាលារៀនស្រែកសិករ បណ្តុះបណ្តាលគ្រូបង្គោល កសិករ និងធ្វើបង្ហាញបច្ចេកទេស ការតាមដានវាយតម្លៃកម្មវិធី និងសកម្មភាពសាលារៀនស្រែកសិករ។ អ្នកបច្ចេកទេស និងអ្នកផ្សព្វផ្សាយកសិកម្មប្រើប្រាស់ឯកសារនេះ សម្រាប់បង្កើតនិងរៀបចំកម្មវិធីផ្សព្វផ្សាយ កម្មវិធីបណ្តុះបណ្តាលកសិករ និងផែនការអភិវឌ្ឍភូមិ ឃុំ។ល។ ចំពោះមន្ត្រីផ្សព្វផ្សាយវិញឯកសារនេះជួយផ្តល់ជាមេរៀននិងជំនាញដោយផ្ទាល់ សម្រាប់អនុវត្តក្នុងការបណ្តុះបណ្តាលកសិករ ។

### សារៈសំខាន់គោលការណ៍ណែនាំសាលារៀនស្រែកសិករមាន៖

- ជួយដល់មន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយឱ្យអនុវត្តសកម្មភាពសាលារៀនស្រែកសិករបានរលូនល្អទៅតាមពេលវេលា
- រៀបចំ និងអនុវត្ត សកម្មភាពនីមួយៗទទួលលទ្ធផលជាក់លាក់ និងច្បាស់លាស់
- ធានាបានឱ្យកសិករយល់ដឹងពីគោលបំណងនៃសកម្មភាពនីមួយៗ
- ធានាបាន ទាំងអ្នកសម្របសម្រួល និងកសិករស្គាល់តួនាទីរបស់ខ្លួន
- អ្នកសម្របសម្រួលរៀបចំបានល្អគ្រប់ប្រធានបទ និងបច្ចេកទេសបណ្តុះបណ្តាល
- ធានាឱ្យមានធនធាន និងសម្ភារចាំបាច់គ្រប់គ្រាន់សម្រាប់សាលារៀនស្រែកសិករ។

# ជំពូកទី ១

# គោលគំនិត លក្ខណៈ និងគោលការណ៍សាលារៀនស្រែកសិករ

## ១. ប្រវត្តិសាលារៀនស្រែកសិករ

វិធីសាស្ត្រសាលារៀនស្រែកសិករ បានបង្កើតឡើងដោយគម្រោងរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (អង្គការហ្វាវ) នៅតំបន់អាស៊ី-អាគ្នេយ៍ជាមួយកសិករដាំដំណាំស្រូវ ដើម្បីឱ្យកសិករស្រាវជ្រាវ និងសិក្សា ដោយខ្លួនគាត់ផ្ទាល់។ ពាក្យសាលារៀនស្រែកសិករមកពីពាក្យឥណ្ឌូនេស៊ី (Indonesian Sekolar Lampangan) មានន័យថា **សាលារៀនស្រែ**។ សាលារៀនស្រែកសិករដំបូងបានបង្កើតឡើងឆ្នាំ១៩៨៩ នៅភាគកណ្តាលនៃកោះជ្វា (Central Java) ប្រទេសឥណ្ឌូនេស៊ីដោយគម្រោងសាកល្បងរបស់អង្គការហ្វាវជួយកម្មវិធីជាតិស្តីពី **"វិធានការណ៍ ចម្រុះការពារដំណាំ"** របស់ឥណ្ឌូនេស៊ី។ ក្រោយមកសាលារៀនស្រែកសិករបានទទួលយកមកប្រើ និងពង្រីកនៅក្នុងប្រទេសក្នុងតំបន់អាស៊ីមានប្រទេសហ្វីលីពីន វៀតណាម កម្ពុជា ថៃ ប្រទេសចិន តាមរយៈកម្មវិធី IPM កម្មវិធី FARM (FAO/UNDP) ក្នុងគម្រោងវិធានការណ៍ចម្រុះគ្រប់គ្រងដីជាតិដី និងកម្មវិធីសន្តិសុខស្បៀង ហើយបានពង្រីក ដល់ប្រទេសមួយចំនួននៅទ្វីបអាហ្វ្រិច និងតំបន់អាមេរិកឡាទីន។

## ២.គោលគំនិត និងទស្សនៈទានសាលារៀនស្រែកសិករ

### ២.១. និយមន័យសាលារៀនស្រែកសិករ

សាលារៀនស្រែកសិករ គឺជាវេទិកា និងសាលារៀនគ្មានជញ្ជាំង សម្រាប់បង្កើនសមត្ថភាពសម្រេចចិត្តរបស់កសិករ និងសហគមន៍កសិករប្រមូលផ្តុំនូវបច្ចេកទេសនៅមូលដ្ឋាននិងបច្ចេកទេសថ្មីៗសមស្រប។ សាលារៀនស្រែកសិករជាឧបករណ៍និងវិធីសាស្ត្រសម្រាប់ផ្សព្វផ្សាយបច្ចេកទេសដែលផ្តល់អាទិភាព ឱ្យកសិករ ជ្រើសរើសទៅប្រើប្រាស់ក្នុងផលិតកម្មកសិកម្ម ដោយផ្អែកលើវិធីសាស្ត្រសិក្សាស្រាវជ្រាវរុករកដោយផ្ទាល់។

សាលារៀនស្រែកសិករក៏ជាឧបករណ៍មួយរបស់កម្មវិធីផ្សព្វផ្សាយកសិកម្ម និងគម្រោងអភិវឌ្ឍសហគមន៍ និងកសិកម្មចម្រុះនានានៅកម្ពុជាសម្រាប់អនុវត្តការអប់រំ ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលដោយមានការចូលរួមពីក្រុមពហុជំនាញរួមមាន៖ ផ្នែកដាំដុះដំណាំមាន ការគ្រប់គ្រងដំណាំ ការគ្រប់គ្រងដីជាតិដី វិធានការណ៍ចម្រុះការពារដំណាំ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការគ្រប់គ្រងទឹក យេនឌ័រ អាហាររូបត្ថម្ភ និងការអប់រំពីសុខភាព-អនាម័យ ការគ្រប់គ្រងកសិដ្ឋាន (អាជីវកម្មកសិកម្ម និងសហគ្រាសកសិកម្ម) និងឥណទាន។ល។

សាលារៀនស្រែកសិករ ក៏ជាឧបករណ៍សម្រាប់វាយតម្លៃដំណើរការវិវត្ត ប្រចាំសប្តាហ៍ និងឧបសគ្គលើបច្ចេកទេសផលិតកម្មកសិកម្ម សកម្មភាពនានា និងការប្រែប្រួលជីវភាពរស់នៅនៅភូមិ ឬតំបន់គោលដៅរបស់កម្មវិធី និង គម្រោងនានា ។

ម៉្យាងវិញទៀតសាលារៀនស្រែកសិករ គឺជួយពង្រឹងការងារសហគមន៍ពាក់ព័ន្ធកសិកម្មនានា ដូចជា សហគមន៍អភិវឌ្ឍន៍កសិកម្ម សហគមន៍ប្រើប្រាស់ទឹក សហគមន៍ចិញ្ចឹមសត្វ សហគមន៍ឥណទានខ្នាតតូចនានាជាដើម ។ល។

សាលារៀនស្រែកសិករមានន័យមកពី សាលារៀន-ស្រែ-កសិករ ដោយសិក្សាពីអ្វីដែលកើតមានឡើងនៅ ក្នុងស្រែ ឬចំការ ឬភូមិ និងមានការពិភាក្សាចូលរួមដោះស្រាយនូវបញ្ហា និងសម្រេចចិត្ត។

ការកំណត់រៀបចំសាលារៀនស្រែកសិករ ឬការបណ្តុះបណ្តាលកសិករ **តើត្រូវធ្វើពីអ្វី? អ្នកណាចូលរួម? ត្រូវរៀបចំនៅកន្លែងណា? តើត្រូវធ្វើដូម្តេច? ធ្វើនៅពេលណា ហើយប្រើរយៈពេលប៉ុន្មាន?**

## ២.២. គោលបំណងសាលារៀនស្រែកសិករ

គោលបំណងសាលារៀនស្រែកសិករ គឺនាំឱ្យកសិករធ្វើការជាមួយគ្នា ដើម្បីប្រមូលផ្តុំ និងសហការរិះរកនូវ ការផ្តួចផ្តើមសកម្មភាពរួមគ្នាដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើង។

**គោលបំណងលម្អិតនៃសាលារៀនស្រែកសិករមាន៖**

- ផ្តល់អំណាចដល់កសិករជាមួយចំណេះដឹង និងជំនាញដើម្បីឱ្យពួកគាត់ក្លាយជាអ្នកជំនាញ និងកសិករអាជីព
- បង្កើនសមត្ថភាពកសិករដើម្បីឱ្យគាត់ចេះដោះស្រាយបញ្ហា និងធ្វើការសម្រេចចិត្ត ដើម្បីបង្កើនប្រាក់ចំណូល និងនិរន្តរភាពផលិតភាពកសិកម្មនៅក្នុងកសិដ្ឋាន
- ដើម្បីឱ្យកសិករយល់ដឹងនូវវិធីសាស្ត្រថ្មីក្នុងការគិត និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងបញ្ហាបច្ចេកទេស ទុន ទឹក ធាតុចូលនានា និងទីផ្សារជាដើម
- ជួយកសិករសិក្សាឱ្យចេះចាត់ចែង និងរៀបចំដោយខ្លួនគាត់ និងក្នុងសហគមន៍របស់គាត់។

**សាលារៀនស្រែកសិករក៏ចូលរួមស្របតាមគោលដៅខាងក្រោម៖**

១. ប្រើរយៈពេលខ្លីក្នុងការទទួលបានលទ្ធផលស្រាវជ្រាវពីវិទ្យាស្ថានស្រាវជ្រាវ និងស្ថានីយ៍ពិសោធន៍ទទួលយកទៅអនុវត្តក្នុងស្រែចំការរបស់កសិករដោយមានការចូលរួមស្រាវជ្រាវពីកសិករក្នុងដំណើរការអភិវឌ្ឍបច្ចេកទេស។

២.លើកកម្ពស់សមត្ថភាពមន្ត្រីផ្សព្វផ្សាយក្នុងការធ្វើការ និងសហការជាមួយអ្នកស្រាវជ្រាវ

ធ្វើខ្លួនឱ្យក្លាយជាអ្នកសម្របសម្រួលកសិករក្នុងការសិក្សាដោយស្រាវជ្រាវរុករកពីការផ្លាស់ប្តូរបទពិសោធន៍ និងការចូលរួម។

៣. បង្កើនឯកទេសជំនាញរបស់កសិករ ក្នុងការសម្រេចចិត្តនៅក្នុងស្រែចំការរបស់គាត់។

៤. បង្កើតការទំនាក់ទំនងក្រុមកសិករ រវាងអ្នកសម្របសម្រួលការងារ អ្នកស្រាវជ្រាវ និងអ្នកផ្សព្វផ្សាយដើម្បីផ្តល់សេវាបច្ចេកទេសតាមតម្រូវការរបស់កសិករ ។

## ៣. គោលការណ៍សាលារៀនស្រែកសិករ

ក្នុងសាលារៀនស្រែកសិករគឺផ្អែកលើគោលការណ៍អប់រំមនុស្សពេញវ័យ និងការអប់រំក្រៅប្រព័ន្ធដោយផ្តោតទៅលើការសិក្សាពីបទពិសោធន៍ រៀនសូត្រដោយមនសិការ និងការសិក្សាដោយសេរីភាព និងមានការជាប់ទាក់ទងទៅក្នុងក្សេត្រ-បរិស្ថានសំខាន់ៗ។

វិធីសាស្រ្តបណ្តុះបណ្តាល គឺផ្អែកលើការសិក្សាដោយអនុវត្តផ្ទាល់ ការស្រាវជ្រាវរុករក ការផ្លាស់ប្តូរបទពិសោធន៍រវាងកសិករ និងអ្នកសម្របសម្រួល និងសិក្សាដោយមានការពិភាក្សាចូលរួម។

មានគោលការណ៍សំខាន់ៗ៤ ក្នុងដំណើរការសាលារៀនស្រែកសិករៈ

ក. របរកសិកម្មមានការដាំដំណាំឬចិញ្ចឹមសត្វដែលធន់ទ្រាំ មានសុខភាព ការលូតលាស់ល្អ និងមានផលិតភាព

ខ. ចុះសង្កេតស្រែជាប្រចាំ

គ. រក្សាសត្វ និងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ

ឃ. កសិករយល់ដឹងពីប្រព័ន្ធអេកូឡូស៊ី និងក្លាយជាជំនាញការ និងកសិករអាជីពនៅក្នុងមុខរបររបស់គាត់។

**គោលការណ៍សាលារៀនស្រែកសិករនិងការអប់រំក្រៅប្រព័ន្ធសម្រាប់មនុស្សពេញវ័យៈ** សាលារៀនស្រែកសិករយើងត្រូវគិតថាកសិករ ឬមនុស្សពេញវ័យមាន និងសំបូរទៅដោយបទពិសោធន៍ និងចំណេះដឹងរួចទៅហើយ។ ដូចនេះសាលារៀនស្រែកសិករត្រូវផ្តោត លើការផ្តល់ចំណេះដឹង និងជំនាញគ្រឹះសំខាន់ៗនូវអ្វីដែលកើតមានជាក់ស្តែងនៅចំពោះមុខដល់បរិស្ថានរស់នៅរបស់កសិករ និងអ្វីដែលកើតមានឡើងដល់អសន្តិសុខស្បៀងនិងភាពងាយរងគ្រោះរបស់កសិករ។ **ជាគោលការណ៍យើងត្រូវដឹងថាៈ**

- កាលណាខ្ញុំឮ ខ្ញុំភ្លេចវា
- កាលណាខ្ញុំឃើញ ខ្ញុំអាចចាំវា
- កាលណាខ្ញុំរុករកស្រាវជ្រាវអំពីវា ខ្ញុំជាម្ចាស់សម្រាប់ជីវិតរស់នៅរបស់ខ្ញុំ ។

ក្នុងសាលារៀនស្រែកសិករ អ្នកសម្របសម្រួលត្រូវមានបច្ចេកទេសរឹងមាំ មានជំនាញនិងទេពកោសល្យគ្រប់គ្រាន់។ ដូចនេះគោលការណ៍គ្រឹះសាលារៀនស្រែកសិករមានៈ

១. **រៀនពីការស្រាវជ្រាវរុករកដោយផ្ទាល់:** មានទីកន្លែងដែលបញ្ហា ស្រែ ឬអ្វីដែលយើងចង់ដឹង ជាប្រភពនៃការសិក្សាក្នុងនោះមាន ការចុះពិនិត្យស្រែ ឬទីកន្លែងដោយផ្ទាល់ និងហេតុការណ៍អ្វីដែលកើតមានឡើង ។

២.**បទពិសោធន៍ជាមូលដ្ឋានគ្រឹះសម្រាប់សិក្សា:** មានការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក។

៣. **ការចូលរួមជាមូលដ្ឋានគ្រឹះនៃការសិក្សា:** មានការចូលរួមពិភាក្សា ការបញ្ចេញយោបល់ ។ល។

៤. **ការសិក្សាមានរយៈពេលមួយរដូវកាល**លូតលាស់របស់ដំណាំ សត្វ ឬមួយវដ្តនៃដំណើរការប្រធានបទ អ្វីមួយ ។

៥. កម្មវិធីសិក្សាគឺ អាស្រ័យតាមលក្ខខណ្ឌតំបន់ និងតាមតម្រូវការរបស់កសិករ ។

## អ្វីដែលសំខាន់សម្រាប់អ្នកសម្របសម្រួលត្រូវដឹងក្នុងសាលារៀនស្រែកសិករគឺ:

- កសិករអាចចាំបាន ឬនឹកឃើញ ២០ % នូវអ្វីដែលគាត់បានឮ
- កសិករអាចចាំបាន និងនឹកឃើញ ៥០% នូវអ្វីដែលគាត់បានឃើញ
- កសិករអាចនឹកឃើញនិងចាំបាន ៨០%នូវអ្វីដែលគាត់បានស្រាវជ្រាវ និងធ្វើផ្ទាល់ដោយខ្លួនគាត់។

ដូច្នេះអ្នកសម្របសម្រួលត្រូវតែចងចាំ និងអនុវត្តគោលការណ៍គ្រឹះរបស់សាលារៀនស្រែកសិករក្នុងការរៀបចំ និងធ្វើដំណើរការអនុវត្តសាលារៀនស្រែកសិករ ។

<u>ល្បែង ៩ ចំណុច:</u>



**សួរកសិករឱ្យលើកបញ្ហាដែលពួកគាត់ជួបប្រទះក្នុងជីវភាពរស់នៅរបស់គាត់ឱ្យបាន ៩ចំណុច**

## លក្ខណៈសម្បត្តិរបស់អ្នកសម្របសម្រួល

<u>**ត្រូវធ្វើខ្លួនជាអ្នកស្តាប់សកម្មម្នាក់:**</u> អ្នកសម្របសម្រួលល្អ បង្ហាញការចាប់អារម្មណ៍នូវអ្វីដែលសិក្ខាកាមចង់និយាយ ត្រូវស្តាប់ឱ្យជិត ដើម្បីធ្វើការសង្ខេប ឬសម្រួលប្រយោគនូវអ្វីដែលគាត់បាននិយាយ ហើយ

លើកយកមកពិភាក្សានិង លើកមកវិភាគ ឬវិនិច្ឆ័យ។ ការស្តាប់យ៉ាងយកចិត្តទុកដាក់នេះ ជាគន្លឹះដល់គ្រប់ជំនាញសម្របសម្រួល ។

**ធ្វើខ្លួនជាអ្នកសង្កេតការម្នាក់**: អ្នកសម្របសម្រួលល្អ ត្រូវកត់សំគាល់សកម្មនូវសកម្មភាពរបស់ក្រុម ដោយ សង្កេតមើល តើអ្នកណានិយាយ? អ្នកណាមិននិយាយ? និងតើក្រុមទាំងនោះសមាជិកមានអន្តរអំពើទៅវិញទៅមកដូចម្តេច? **ឧទាហរណ៍**៖ ស្ត្រី និងបុរស ឬជនជាតិផ្សេងៗគ្នា។ ត្រូវប្រើការសង្កេតដើម្បីដឹងថា តើវិធីសាស្ត្រ និងពេលវេលាខុសៗគ្នាអាចប្រើបានទេ ដើម្បីដឹងជាក់ថា តើអ្នករាល់គ្នាមានឱកាសចូលរួមដែរឬទេ? ។

**សួរសំណួរ**: អ្នកសម្របសម្រួលល្អ ប្រើសំណួរដើម្បីចាប់ផ្តើមដោយផ្តោត និងស៊ីជម្រៅទៅលើការសិក្សារបស់សិក្ខាកាម។ សំណួរសមញ្ញដូចជា៖ ហេតុអ្វី? គឺគ្រប់គ្រាន់សម្រាប់ការពិភាក្សាមួយឱ្យស៊ីជម្រៅ។ សំណួរអាចប្រើ អ្នកណា? អ្វី? ពេលណា? កន្លែងណា? គឺជាសំណួរល្អសម្រាប់លើកយកមកលម្អិត ។

**សំណួរអាចបត់បែនបាន**: អ្នកសម្របសម្រួលល្អ ត្រូវឆ្លើយតបនឹងតម្រូវការរបស់សិក្ខាកាម និងមានចិត្តចង់ ទទួលយក ឬផ្លាស់ប្តូរវិធីសាស្ត្រ ឧបករណ៍ និងសំណួរដើម្បីសម្របទៅតាមកាលៈទេសៈ។

**រៀបចំឲ្យបានល្អ**: អ្នកសម្របសម្រួលល្អ គឺរៀបចំ និងចាត់ចែងបានល្អរាល់សម្ភារ និងការងាររៀបចំទីកន្លែង ត្រូវរៀបចំជាស្រេច ជៀសវាងធ្វើឱ្យខាតបង់ពេលវេលា និងធ្វើមិនបានសម្រេច។

**ជាមនុស្សចេះដឹងហើយច្បាស់លាស់**: អ្នកសម្របសម្រួលល្អ ត្រូវមានចំណេះដឹងគ្រប់គ្រាន់អំពីការអភិវឌ្ឍ ការទំនាក់ទំនងមានលក្ខណៈសាមញ្ញ និងសួរចំចំណុចនៃសំណួរ។ អ្នកសម្របសម្រួលល្អនិយាយភាសាសមរម្យ មិនប្រើពាក្យគ្រោតគ្រាត ។

**ត្រូវធ្វើជាអជ្ញាកណ្តាលតែមិនធ្វើជាអ្នកត្រួតត្រា**: អ្នកសម្របសម្រួលល្អ ត្រូវស្គាល់អំពីពេលវេលាណាធ្វើអន្តរាគមន៍ នៅពេលពិភាក្សា និងពេលណានៅស្ងៀម។ អ្នកសម្របសម្រួលត្រូវផ្អែកលើការផ្លាស់ប្តូរចំណេះដឹងរបស់សិក្ខាកាមនិងផ្តល់ការណែនាំនៅពេលដែលមិនច្បាស់និងការចាប់ផ្តើមពិភាក្សាចាកប្រធានបទ។

## ៤. លក្ខណៈសាលារៀនស្រែកសិករ

**កសិករជាអ្នកជំនាញការ និងជាកសិករអាជីព**: កសិករសិក្សាដោយអនុវត្តផ្ទាល់ ពួកគាត់អនុវត្តដោយខ្លួនគាត់នូវសកម្មភាពជាច្រើនពីការងារអនុវត្តនៅក្នុងស្រែចំការតាមអ្វីដែលពួកគាត់ចង់សិក្សាដូចជា៖ ការដាំដំណាំ ការចិញ្ចឹមសត្វ វារីវប្បកម្ម កសិពាណិជ្ជកម្មនិងកសិ-រុក្ខកម្មជាដើម។ ចំណុចសំខាន់គឺកសិករសិក្សានៅក្នុងស្រែចំការរបស់គាត់ផ្ទាល់។

**ស្រែចំការជាកន្លែងសិក្សា**: រាល់ការសិក្សាគឺនៅក្នុងស្រែចំការ ដោយវាលស្រែ ឬចំការដំណាំជាកន្លែងដែលកសិករ រៀនដោយចែកពួកគាត់ជាក្រុមតូចៗឬចុះសង្កេត ដើម្បីប្រមូលទិន្នន័យនៅក្នុងស្រែវិភាគទិន្នន័យ និងធ្វើការសម្រេចចិត្ត។

**អ្នកផ្សព្វផ្សាយជាអ្នកសម្របសម្រួលមិនមែនជាគ្រូបង្រៀនទេ**:តួនាទីអ្នកផ្សព្វផ្សាយនៅក្នុងសាលារៀន ស្រែកសិករគឺជាអ្នកសម្របសម្រួល។ កសិករម្នាក់ៗគាត់ដឹងថាតើអ្វីដែលគាត់ត្រូវធ្វើនៅក្នុងស្រែ គាត់អាចធ្វើការសង្កេតនៅក្នុងស្រែដោយមន្ត្រីគ្រាន់តែណែនាំពីបច្ចេកទេស និងវិធីសាស្ត្រអនុវត្ត។

**អ្នកស្រាវជ្រាវ និងមន្ត្រីបច្ចេកទេសធ្វើការជាមួយកសិករ ជៀសវាងធ្វើជាអ្នកបង្រៀន**: តួនាទីអ្នកស្រាវជ្រាវ និងមន្ត្រីបច្ចេកទេសគឺជាអ្នកផ្តល់ការគាំទ្របច្ចេកទេសដល់សមាជិកកសិករក្នុងសាលារៀនស្រែកសិករ ហើយត្រូវសិក្សាធ្វើការ ដោយផ្តល់ការប្រឹក្សាសមត្ថភាពបច្ចេកទេសជាមួយកសិករ។

**កម្មវិធីសិក្សាត្រូវមានចម្រុះ:** កម្មវិធីសិក្សាសាលារៀនស្រែកសិករត្រូវមានចម្រុះតាមវដ្តលូតលាស់របស់ដំណាំ និងសត្វ ដោយមានការធ្វើការវិភាគក្សេត្រ-បរិស្ថាន និងវិភាគសេដ្ឋកិច្ចច្បាស់លាស់។

**ការសិក្សាអនុវត្តមួយរដូវកាល**: ការសិក្សាគឺត្រូវធ្វើមួយវដ្តរដូវកាល និងវដ្តជីវិតរបស់ដំណាំ ឬសត្វ។ ចំពោះដំណាំ ប្រចាំរដូវ ត្រូវធ្វើចាប់ពីការរៀបចំដីរហូតដល់ពេលប្រមូលផល។ ចំពោះដំណាំឈើហូបផ្លែវិញ ត្រូវអនុវត្តពីការថែទាំ លាស់មែក ផ្កា រហូតដល់ពេលប្រមូលផល។ល។

**មានការប្រជុំជាប្រចាំ**: កសិករត្រូវឯកភាពជួបគ្នាក្នុង១សប្តាហ៍ ឬ២សប្តាហ៍ម្តង រយៈពេល១ព្រឹក ឬល្ងាចជា ប្រចាំក្នុងរយៈពេលរដូវដាំដុះដំណាំ ឬចិញ្ចឹមសត្វ។ សម្រាប់ដំណាំឈើ ឬកសិ-រុក្ខកម្មវិញ គឺអាស្រ័យតាមសកម្មភាពជាក់លាក់ណាមួយ។

**សម្ភារសិក្សា គឺបង្កើតដោយអ្នកចូលរួម**៖ កសិករបង្កើតសម្ភារសិក្សាដោយខ្លួនឯងពីអ្វីដែលគាត់បានគូរនូវអ្វីដែលគាត់បានសង្កេតឃើញនៅក្នុងស្រែ។ សម្ភារទាំងនោះ ជាទូទៅស្របទៅនឹងអ្វីដែលកើតមានឡើងនៅក្នុងស្រែ។ អ្នកសម្របសម្រួលអាចប្រើសម្ភារសិក្សាដែលផលិតដោយអ្នកជំនាញផលិតសម្ភារផ្សព្វផ្សាយជំនួយជាមេរៀនពិសេស មានផ្ទាំងផ្សព្វផ្សាយព័ត៌មានកសិកម្មធំៗ ខិតប័ណ្ណបច្ចេកទេស និងរូបភាពវីដេអូ ។ល។

**ការស្ថាបនាក្រុម**: សិក្សារួមបញ្ចូលការកសាងជំនាញទំនាក់ទំនង ការដោះស្រាយបញ្ហា ការដឹកនាំ និងវិធីពិភាក្សា។ កសិករត្រូវការជំនាញទាំងនេះ ហើយភាពជោគជ័យនៅក្នុងសហគមន៍គឺកសិករចេះអនុវត្តការដឹកនាំ ប្រកបដោយប្រសិទ្ធភាព និងមានសមត្ថភាពទំនាក់ទំនងជាមួយកសិករផ្សេងៗទៀត។

សាលារៀនស្រែកសិករ ត្រូវរៀបចំក្នុងគោលបំណងបង្កើតឱ្យមានបរិយាកាសសិក្សាដោយឱ្យកសិករអាចបង្រៀន និងអនុវត្តជំនាញគ្រប់គ្រងធនធានរបស់គាត់។ នេះផ្តោតលើការផ្តល់អំណាចដល់កសិករក្នុងការអនុវត្ត និងការសម្រេចចិត្តនៅក្នុងស្រែរបស់គាត់។

**តារាងទី១. ការប្រៀបធៀបសាលារៀនស្រែកសិករ និងការបង្រៀនបច្ចេកទេស**

| ប៉ារ៉ាម៉ែត្រ | សាលារៀនស្រែកសិករ | ការបង្រៀនបច្ចេកទេស |
| --- | --- | --- |
| ១. វិធីសាស្ត្រសិក្សា | ដោយអនុវត្តផ្ទាល់ ការធ្វើពិសោធន៍ ស្រាវជ្រាវរុករក | បកស្រាយ និងការស្តាប់ |
| ២. ទីកន្លែងសិក្សា | តាមប្រធានបទសិក្សានៅស្រែ ចំការ ដំណាំ សត្វ | នៅក្នុងអាគារសាលា ឬមណ្ឌលសិក្សា |
| ៣. រយៈពេល | សិក្សាមួយវដ្តដំណាំឬសត្វ រយៈពេល ១រដូវ | ១ ទៅ ២ថ្ងៃ |
| ៤. អ្នកផ្សព្វផ្សាយ និងតួនាទី | ជំនាញបណ្តុះបណ្តាល ជាអ្នកសម្របសម្រួលកសិករ | ប្រើពេលច្រើនដើម្បីពន្យល់ឱ្យកសិករ ជឿ |
| ៥.កសិករនិងតួនាទីរបស់គាត់ | អ្នកចូលរួមពិភាក្សា ជាអ្នកស្ថាបនា ជាអ្នកសម្រេចចិត្ត | ជាអ្នកស្តាប់ |
| ៦. គុណភាពក្នុងការចូលរួម | មិនមានជម្លោះចូលរួមពិភាក្សា | កសិករត្រូវកត់ត្រាមេរៀន |
| ៧.កម្មវិធីសិក្សា និងផែនការ | ធ្វើដោយមានការឯកភាពជាមួយកសិករ ហើយអ្នកផ្សព្វផ្សាយត្រូវគោរពតាមពេលវេលា | រៀបចំដោយមន្ត្រីផ្សព្វផ្សាយ នៅការិយាល័យ មិនធានាថាគោរពតាមកម្មវិធី |
| ៨.ការវាយតម្លៃនិងទទួលយក | ធ្វើជាមួយកសិករ កសិករទទួលយកតាមជម្រើសរបស់ពួកគាត់ | ធ្វើនៅការិយាល័យ |

# ជំពូកទី ២
# ការរៀបចំ និងដំណើរការសាលារៀនស្រែកសិករ

## ១. ជំហាននៃ ការរៀបចំសាលារៀនស្រែកសិករ

ជំហានការនៃការរៀបចំសាលារៀនស្រែកសិករមានដូចខាងក្រោមៈ

១. រៀបចំការបណ្តុះបណ្តាលអ្នកសម្របសម្រួល (គ្រូបង្គោល)

២. កំណត់ប្រធានបទ ទីកន្លែង និងកសិករចូលរួម(ការវាយតម្លៃតម្រូវការកសិករ និងការធ្វើផែនការដោយចុះប្រមូល និងវាយតម្លៃ វិភាគព័ត៌មាន និងធ្វើ ផែនការសាលារៀនស្រែកសិករ)

៣. ការរៀបចំ និងដំណើរការសាលារៀនស្រែកសិករ

៤. ការវាយតម្លៃសាលារៀនស្រែកសិករ និងការធ្វើបង្ហាញ

៥. ការធ្វើទិវាស្រែ  និងបិទវគ្គសាលារៀនស្រែកសិករ

៦. កសិករគាំទ្រដំណើរការសាលារៀនស្រែកសិករ

៧. ការតាមដានបន្តរបស់អ្នកសម្របសម្រួល។

**<u>រូបទី៣</u>. ជំហានសំខាន់ទាំង៧ ក្នុងការរៀបចំសាលារៀនស្រែកសិករ**




### ១.១. ការបណ្តុះបណ្តាលគ្រូបង្គោល

ការបណ្តុះបណ្តាលគ្រូបង្គោលជាដំណាក់កាលទី១ នៃកម្មវិធីផ្សព្វផ្សាយកសិកម្មដែលបណ្តុះបណ្តាល ពីមូលដ្ឋានគ្រឹះនៃការផ្សព្វផ្សាយ និងបច្ចេកទេសពីវិធីសាស្ត្រជំនាញផ្សព្វផ្សាយ សម្របសម្រួល និងបច្ចេកទេស ជំនាញចាំបាច់នានាដល់មន្ត្រីផ្សព្វផ្សាយ មន្ត្រីបច្ចេកទេស ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និង

កសិករគ្រូជាដើម។ ការបណ្តុះបណ្តាលមន្ត្រី គ្រូបង្គោលត្រូវអនុវត្តយ៉ាងតិច២សប្តាហ៍ មុនពេលអនុវត្តសកម្មភាពផ្សព្វផ្សាយសាលារៀនស្រែកសិករនៅមូលដ្ឋាន។

ការបណ្តុះបណ្តាលគ្រូបង្គោល គឺមានគោលបំណងបង្កើនសមត្ថភាពមន្ត្រី និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងអ្នកសម្របសម្រួល ពីវិធីសាស្ត្រនិងបច្ចេកទេសថ្មីៗសម្រាប់សម្របសម្រួលក្នុងសាលារៀនស្រែកសិករ។ គោលបំណងលម្អិតក្នុងការ បណ្តុះបណ្តាលមាន៖

- បណ្តុះបណ្តាលពីទស្សនៈទាន នៃវិធីសាស្ត្រផ្សព្វផ្សាយដោយមានការចូលរួមរបស់កសិករ
- ដំណើរការរៀបចំសាលារៀនស្រែកសិករ និងសកម្មភាពនៅទីវាលនានា
- កសាងសមត្ថភាពភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ពីវិធីសាស្ត្របណ្តុះបណ្តាល និងផ្សព្វផ្សាយដោយមានការចូលរួមមាន៖ វិធីសាស្ត្រសម្របសម្រួលក្នុងស្រែកសិករ ការធ្វើស្រែបង្ហាញ ទិវាស្រែ និងការរៀបចំ និងដំណើរការក្រុមសន្សំ
- បណ្តាលពីជំនាញទំនាក់ទំនង ការដោះស្រាយបញ្ហា ភាពជាអ្នកដឹកនាំ និងវិធីសាស្ត្រសម្របសម្រួលស្រែកសិករ
- ទស្សនៈនិងចំណេះដឹងពីការប្រែប្រួលអាកាសធាតុ និងការបន្សាំ និងបន្ធូរបន្ថយការប្រែប្រួលអាកាសធាតុលើកសិកម្ម
- ការកែលំអបច្ចេកទេសផលិតកម្មដំណាំ ចិញ្ចឹមសត្វ ប្រព័ន្ធកសិកម្មចម្រុះ កសិកម្មអភិរក្សការចិញ្ចឹមត្រី និងវារីវប្បកម្ម និង កសិរុក្ខកម្ម
- អាជីវកម្មកសិកម្មនិងទីផ្សារ។ល។

## ១.២. ការកំណត់ប្រធានបទ ទីកន្លែង និងកសិករចូលរួម

ការកំណត់ប្រធានបទ ទីកន្លែង និងកសិករចូលរួមក្នុងសាលារៀនស្រែកសិករមាន៖

- កំណត់បញ្ហាដែលកសិករជួបប្រទះ
- កំណត់បច្ចេកទេសបច្ចេកវិទ្យា និងការអនុវត្តកសិកម្មល្អនានា សម្រាប់អនុវត្តក្នុងសាលារៀនស្រែកសិករ និងធ្វើស្រែបង្ហាញ
- កំណត់កសិករចូលរួមពី ២៥ ទៅ៣០ នាក់ក្នុងសាលារៀនស្រែកសិករ
- កំណត់ទីកន្លែងសាលារៀនស្រែកសិករ និងស្រែបង្ហាញ។ល។

**ក. ចុះជួបជាមួយមន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន៖** ការចុះទំនាក់ទំនងគឺធ្វើឱ្យបានមុនយ៉ាងតិច១៥ ទៅ ៣០ថ្ងៃ មុនពេលចាប់ផ្តើមសាលារៀនស្រែកសិករដោយ៖

- ជួបជាមួយមេឃុំ ក្រុមប្រឹក្សាឃុំ ប្រធានភូមិ គណៈកម្មការអភិវឌ្ឍភូមិ និងចាស់ព្រឹទ្ធាចារ្យនៅក្នុងភូមិ

- ប្រមូលទិន្នន័យបន្ទាប់បន្សំរបស់ភូមិ ឃុំ
- កំណត់ទីកន្លែង និងអ្នកចូលរួម ជ្រើសរើស និងកំណត់ទីកន្លែងសាលារៀនកសិករ៖
    - ជាកន្លែងដែលអាចទទួលយកបានពីកសិករគ្រប់គ្នា
    - រៀបចំមន្ត្រី ថវិកា សម្ភារ និងមធ្យោបាយធ្វើដំណើរ
    - ចុះវាយតម្លៃ ប្រមូលទិន្នន័យ និងធ្វើផែនការសាលារៀនជាមួយកសិករ
    - កំណត់មុខរបរ បញ្ហាសំខាន់ៗក្នុងភូមិ និងរកដំណោះស្រាយ
    - កំណត់ពីតម្រូវការបច្ចេកទេសរបស់កសិករ
    - កំណត់តួនាទីរបស់អ្នកសម្របសម្រួល។

**ខ.ការកំណត់ប្រធានបទ ទីកន្លែង និងកសិករចូលរួមមានគោលដៅលម្អិតដូចខាងក្រោម៖**

- វាយតម្លៃស្ថានភាព និងនិន្នាការព្រមទាំងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើកសិកម្ម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតំបន់ភូមិ ឃុំគោលដៅ
- វាយតម្លៃនូវការយល់ដឹងនិងសមត្ថភាពបន្សាំនិងភាពធន់របស់កសិករនិងសហគមន៍កសិករលើការប្រែប្រួលអាកាសធាតុ
- កំណត់តម្រូវការជម្រើសបច្ចេកទេស និងបច្ចេកវិទ្យា និងការកសាងសមត្ថភាពរបស់កសិករ និងសហគមន៍កសិករដើម្បីបន្សាំ និងពង្រឹកភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅតាមភូមិ ឃុំគោលដៅ
- បង្កើតកម្មវិធីសិក្សានិងម៉ូឌុលបណ្តុះបណ្តុះបណ្តាលលើបច្ចេកទេសកសិកម្មដើម្បីពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុនិងជីវភាពរស់នៅ
- រៀបចំចងក្រងក្រុមកសិករសិក្សា ដោយការជ្រើសរើសកសិករពី២៥ ទៅ៣០នាក់។

**គ. ការលើកគម្រោងផែនការសាលារៀនស្រែកសិករមួយ**

ការលើកគម្រោងចំណាយលើសកម្មភាពក្នុងសាលារៀនមួយត្រូវមានការបណ្តុះបណ្តាលកសិករ ការធ្វើបង្ហាញគំរូជាលក្ខណៈផលិតកម្មគំរូសម្រាប់សិក្សា និងធ្វើទិវាស្រែដែលរួមមាន៖

១. ចំណាយលើអ្នកសម្របសម្រួល (២នាក់ ថ្លៃហូបចុក និងធ្វើដំណើរ)

២. សម្ភារសិក្សា និងអាហារសម្រន់

៣. សម្ភារ និងឧបករណ៍ធ្វើបង្ហាញ

៤. ការៀបចំទិវាស្រែ។ល។

៥.ចំណាយចាំបាច់ផ្សេងៗ។

## ១.៣. ការរៀបចំធ្វើស្រែបង្ហាញ

ការធ្វើបង្ហាញ គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពមួយសម្រាប់បណ្តុះបណ្តាលកសិករ។ ការធ្វើបង្ហាញជាមធ្យោបាយនិងឧបករណ៍មួយនៃសាលារៀនស្រែកសិករ សម្រាប់ជាកន្លែងសិក្សាស្រាវជ្រាវ រុករក វិភាគ

ដោយផ្ទាល់ ផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមករវាងកសិករ និងអ្នកសម្របសម្រួលនូវដំណើរ ការអនុវត្ត បច្ចេកទេស បញ្ហាដែលកើតមានឡើងតាមដំណាក់កាលនីមួយៗរបស់ដំណាំឬសត្វ ឬការធ្វើអាជីវកម្ម និងទីផ្សារកសិកម្ម។

ស្រែបង្ហាញជាកន្លែងវាយតម្លៃ និងបង្ហាញនូវបច្ចេកទេសថ្មីៗដល់កសិករនិងសហគមន៍ កសិករនៅតាមមូលដ្ឋានភូមិ ឃុំនិងក្នុងស្រែ និងកសិដ្ឋានកសិករ និងក្នុងលក្ខខណ្ឌកសិករ ។ ការធ្វើស្រែបង្ហាញគឺដើម្បី៖

- បង្កើនការយល់ដឹង និងការចាប់អារម្មណ៍អំពីបច្ចេកវិទ្យាថ្មី
- បង្ហាញពីផលចំណេញនូវបច្ចេកវិទ្យាថ្មីមួយ និងជួយឱ្យជឿជាក់ក្នុងសាកល្បងនូវបច្ចេកវិទ្យាថ្មី។

ការរៀបចំស្រែបង្ហាញឱ្យបានល្អត្រូវៈ

- រៀបចំឱ្យទៅតាមតម្រូវការ ដោយកំណត់បញ្ហាសំខាន់ៗ និងមូលហេតុ និងធ្វើការជាមួយកសិករដើម្បីកំណត់ជម្រើសប្រធានត្រូវធ្វើបង្ហាញ។
- វាយតម្លៃ និងបង្ហាញបច្ចេកវិទ្យាថ្មី និងការអនុវត្តថ្មី ស្របជាមួយលក្ខខណ្ឌមូលដ្ឋាន
- មានការចូលរួមពិភាក្សា និងទទួលនូវយោបល់ពីមន្ត្រីផ្សព្វផ្សាយអ្នកបច្ចេកទេស និងកសិករ។
- កន្លែងស្រែបង្ហាញត្រូវមានផ្លូវងាយស្រួលចេញចូល ជិតផ្លូវ និងមានស្លាកបង្ហាញពីខ្លឹមសារ និងពិធីសារបង្ហាញ
- មានការប្រៀបធៀបការអនុវត្តបច្ចេកទេស និងទំលាប់របស់កសិករ
- ទំហំការធ្វើបង្ហាញត្រូវទំហំសមស្រប អាចកសិករយកជាគំរូទៅអនុវត្តក្នុងផលិតកម្ម និងអាជីវកម្មបាន
- ស្រែបង្ហាញត្រូវធ្វើជាតំណាងក្នុងតំបន់គោលដៅនិង
- មានការសហការចូលរួមជាមួយពីកសិករជាម្ចាស់ស្រែ និងកសិដ្ឋានពីក្រុមកសិករសិក្សា និងអ្នកសម្របសម្រួល។

គោលការណ៍គ្រឹះនៃការធ្វើបង្ហាញ

- **ការចូលរួមៈ** ការធ្វើស្រែបង្ហាញនៅក្នុងស្រែ និងកសិដ្ឋានកសិករ និងឱ្យកសិករចូលរួមក្នុងការធ្វើបង្ហាញ។
- **មានភាពសមញ្ញ និងងាយស្រួលៈ** ការធ្វើបង្ហាញត្រូវងាយស្រួលអនុវត្ត និងមានការបង្ហាញនូវបច្ចេកទេសមួយ និងមានពិធីសារច្បាស់លាស់។
- **ជាសិក្សាៈ** ត្រូវមានទីកន្លែងដែលមានទំហំទូលាយ មានពេលវេលា និងសម្ភារ និងមានវិធីសាស្រ្តបង្រៀនគ្រប់គ្រាន់។
- **មានការរៀបចំល្អៈ** ការធ្វើស្រែបង្ហាញ ត្រូវការរៀបចំផែនការដោយប្រយ័ត្ន ជាពិសេសពីធីសារធ្វើបង្ហាញ។

សកម្មភាពធ្វើបង្ហាញ៖

- បច្ចេកទេសផលិតកម្មដំណាំស្រូវ ដំណាំបន្លែ ដំណាំរួមផ្សំ ដំណាំឈើហូបផ្លែ
- ការគ្រប់គ្រងដី និងសារធាតុចិញ្ចឹមតាមទីកន្លែងជាក់លាក់
- បច្ចេកទេសចិញ្ចឹមមាន់ ឬទាជាលក្ខណៈគ្រួសារ និងជ្រូកជាលក្ខណៈគ្រួសារ
- បច្ចេកទេសវារីវប្បកម្ម (ត្រី អន្ទង់ កង្កែប....)។ល។

**ការធ្វើស្រែបង្ហាញ និងវាយតម្លៃស្រែបង្ហាញ**

- ពិភាក្សារៀបចំពិធីសារ និងសម្ភារធ្វើស្រែបង្ហាញ
- ប្រមូលទិន្នន័យស្រែបង្ហាញ និងវិភាគទិន្នន័យ
- បកស្រាយ និងធ្វើរបាយការណ៍
- វិភាគសេដ្ឋកិច្ចស្រែបង្ហាញ
- ធ្វើបទបង្ហាញលទ្ធផលស្រែបង្ហាញ។

## ក. ពិធីសារណែនាំពីការធ្វើបង្ហាញបច្ចេកទេសកសិកម្ម

### ១. គោលការណ៍ណែនាំពីការធ្វើបង្ហាញដំណាំស្រូវ

ក. សម្ភារ មានពូជស្រូវ ជី ថ្នាំកសិកម្ម ស្លាកបង្ហាញ។ល។
ទំហំកូនស្រែពិសោធន៍មាន ២០មx២០ ម ទៅ ២០មx៤០ ម

### ២. គោលការណ៍ណែនាំពីការធ្វើបង្ហាញដំណាំបន្លែ

ក. ផ្ទៃដីដាំបន្លែអាចធ្វើរោង ២០មx២០ ម

- ឈើ របារឬស្សី និង
- សំណាញ់ខៀវ
- សំណាញ់ស និងសម្ភារចំបាច់ផ្សេងៗ

ខ. សម្ភារ ពូជដំណាំ ជីគីមី ជីកំប៉ុស្ត

### ៣. គោលការណ៍ណែនាំពីការធ្វើបង្ហាញចិញ្ចឹមជ្រូក

ក. សម្ភារ មាន កូនជ្រូក ២ ក្បាល (តម្លៃពី ៥០ទៅ៧០ដុល្លារ) ចំណី វ៉ាក់សាំង និង ថ្នាំព្យាបាល។ល។

ខ. ទ្រុង និងឧបករណ៍៖ ស៊ីម៉ង់ត៍ ដំបូលស័ង្កសី ថ្ម ខ្សាច់និង ស្នូកទឹក ស្នូកចំណី។ល។

### ៤. គោលការណ៍ណែនាំពីការធ្វើបង្ហាញចិញ្ចឹមមាន់

ក. ពូជមាន់មាន២៥ ក្បាល ទម្ងន់ ១.២ គីឡូក្រាម ក្នុង១ក្បាល(២៣ ញី និងឈ្មោល២ក្បាល)

ខ. ទ្រុង និងឧបករណ៍ សង់ទ្រុងមានប្រក់ដំបូល ៥មx៥ម សំណាញ់ជ័រព័ទ្ធជុំវិញទីធ្លា ១០ មx១៥ ម សម្ភារស្នូកចំណី និងទឹក។ល។ ចំណី ថ្នាំវ៉ាក់សាំង និងថ្នាំព្យាបាល។ល។

### ៥.គោលការណ៍ណែនាំពីការធ្វើបង្ហាញចិញ្ចឹមត្រី

- ធ្វើស្រះទឹក ឬកូនស្រះទ្រាប់កៅស៊ូប្លាស្ទិក
- សម្ភារចាំបាច់នានា
- កូនត្រី
- ចំណីត្រី

**៦.គោលការណ៍ណែនាំពីការធ្វើបច្ចេកទេសការធ្វើបង្ហាញកន្លែងឬឧបករណ៍សន្សំទឹក**

- ធ្វើស្រះទឹក (អាចទ្រាប់កៅស៊ូប្លាស្ទិក)
- ធ្វើអាង ឬលូស្តុកទឹក
- ទំនប់អាងតូចៗនៅទីជម្រាល

សម្ភារស្រោចស្រព (ឧបករណ៍ស្រោចដំណក់ទឹក។ល។

**ឧទាហរណ៍គំរូគម្រោងចំណាយសាលារៀនស្រែកសិករមួយ**

**ឈ្មោះសាលារៀនកសិករៈ.......................ភូមិ .........ឃុំ.....................ស្រុក..............ខេត្ត**

| ល.រ | បរិយាយតាមផលិតកម្ម | ឯកតា | ចំនួនឯកតា | តម្លៃមួយ ឯកតា (រៀល) | ទឹកប្រាក់សរុប (រៀល) |
|---|---|---|---|---|---|
| ក | **វគ្គបណ្តុះបណ្តាលកសិករ** | | | | |
| | ១. អ្នកសម្របសម្រួល | | | | |
| | ២. សម្ភារសិក្សា | | | | |
| | ៣. អាហារសម្រន់ | | | | |
| | ..... | | | | |
| ខ | **ការធ្វើស្រែបង្ហាញ** | | | | |
| | ១.សម្ភារ និងឧបករណ៍បង្ហាញ | | | | |
| | ២. | | | | |
| | ៣. | | | | |
| | ..... | | | | |
| គ | **ទិវាស្រែ និងបិទវគ្គ** | | | | |
| | ១........... | | | | |
| | ២.......... | | | | |
| | ៣............ | | | | |
| | **ចំណាយសរុប** | | | | |

## តារាងទី១. ឧទាហរណ៍ផែនការសាលារៀនស្រែកសិករមួយ

| សកម្មភាព | គោលបំណង | ទីកន្លែង | ពេលវេលា | សម្ភារ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|
| ក. សាលារៀនស្រែកសិករ | | | | | |
| ១. សាលារៀនស្រែកសិករពីផលិតកម្មដំណាំស្រូវក្រអូប ផ្ការំដួល ទី១ | - បង្កើនចំណេះដឹងដល់កសិករផលិតស្រូវដែលមានគុណភាពខ្ពស់ | ភូមិត្រគៀត | មិថុនា-វិច្ឆិកា ២០១៧ | - ក្រដាស ប៊ិច ហ្វឺត<br>- ដី ជី… ។ល។<br>- ជីកំប៉ុស្ត | ក្រុមការងារខេត្តស្រុក និងកសិករ |
| ២. សាលារៀនស្រែកសិករពីផលិតកម្មបន្លែ | -បង្កើនចំណេះដឹងដល់កសិករផលិតបន្លែដែលមានគុណភាពខ្ពស់ | ភូមិ ព្រៃក | មិថុនា-វិច្ឆិកា ២០១៧ | - ក្រដាស ប៊ិច ហ្វឺត<br>- ដី ជី ពូជ<br>- ជីកំប៉ុស្ត | ក្រុមការងារខេត្តស្រុក និងកសិករ |
| ៣.សាលារៀនស្រែកសិករពីផលិតកម្មសត្វ | -បង្កើនចំណេះដឹងដល់កសិករពីផលិតកម្មសត្វ | ភូមិម្កាក់ | មិថុនា-វិច្ឆិកា ២០១៧ | - ក្រដាស ប៊ិច ហ្វឺត<br>- ពូជសត្វ<br>- ចំណី | ក្រុមការងារខេត្តស្រុក និងកសិករ |
| ខ. ស្រែបង្ហាញ | | | | | |
| ១.ស្រែបង្ហាញពីផលិតកម្មស្រូវពូជផ្ការំដួល | -សម្រាប់សិក្សា | ស្រែពូ ឈឹមធឿន | មិថុនា-ធ្នូ ២០១៧ | -ដីស្រែ ពូជដីលាមកគោ | ក្រុមការងារខេត្ត-ស្រុក និងកសិករ |
| ២.ស្រែបង្ហាញពីផលិតកម្មបន្លែ | -សម្រាប់សិក្សា | ស្រែពូ ម៉ៅ ង៉ែត | មិថុនា-ធ្នូ ២០១៧ | -ដីស្រែ ពូជជី | ក្រុមការងារខេត្ត-ស្រុក និងកសិករ |
| ៣.ស្រែបង្ហាញពីផលិតកម្មសត្វ | - សម្រាប់សិក្សា | ស្រែពូ ម៉ាក មឿន | មិថុនា-ធ្នូ ២០១៧ | -ក្រដាស ប៊ិច ហ្វឺត<br>-ពូជសត្វ<br>-ចំណី | ក្រុមការងារខេត្ត-ស្រុក និងកសិករ |

| គ.ផលិតកម្មគំរូ | | | | | |
|---|---|---|---|---|---|
| ១. ស្រែផលិតកម្មគំរូស្រូវពូជផ្ការំដួលឬដំណាំបន្លែ | -សម្រាប់បង្ហាញ និង ផលិតកម្ម | ឃុំចំបុី ចំនួន ២០អា | មិថុនា-ធ្នូ ២០១៧ | - ដីស្រែ ពូជ ជីលាមកគោ | ក្រុមការងារខេត្ត-ស្រុក និងកសិករ |
| ២.ស្រែផលិតកម្មគំរូសត្វៈ មាន់ ជ្រូក | -សម្រាប់បង្ហាញនិង ផលិតកម្ម | ឃុំចំបុី ចំនួន២ កន្លែង | មិថុនា-ធ្នូ ២០១៧ | -ក្រដាស ប៊ិច ហ្វឺត -ពូជសត្វ -ចំណី | ក្រុមការងារខេត្ត-ស្រុក និងកសិករ |
| ឃ.ទិវាស្រែ | ដើម្បីបង្ហាញលទ្ធផលសាលារៀនស្រែកសិករ | ឃុំចំបុី | ធ្នូ ២០១៧ | រោង តុ កៅអី អាហារ | រដ្ឋអំណាចមូលដ្ឋានក្រុមការងារខេត្ត-ស្រុក និងកសិករ និងសិស្សនិស្សិត |

## តារាងទី២.គំរូកម្មវិធីសិក្សាសាលារៀនស្រែកសិករចម្រុះសម្រាប់រដូវវស្សាឬប្រាំងឆ្នាំ ២០១៧

| ពេលវេលា | ប្រធានបទ និងសកម្មភាព | អ្នកទទួលខុសត្រូវ |
|---|---|---|
| សប្តាហ៍ទី១ | • ការចុះឈ្មោះអ្នកចូលរួម<br>• ពិធីបើកវគ្គសាលារៀនស្រែកសិករផ្លូវការ<br>• ការណែនាំអ្នកចូលរួម និងបែកចែកក្រុមកសិករសិក្សា<br>• ការប្រឡងសាកកសិករចូលរួម<br>• ការរៀបចំស្រែបង្ហាញ (ស្រូវ និងមាន់)(បន្លែ និងជ្រូក) សម្រាប់សាលារៀនស្រែកសិករ<br>• ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• រដ្ឋអំណាចមូលដ្ឋាន<br>• កសិករចូលរួម |
| សប្តាហ៍ទី២ | • ការចុះឈ្មោះអ្នកចូលរួម<br>• តួនាទីយេនឌ័រនិងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម<br>  ○ លំហាត់ចាប់ផ្តើម<br>  ○ ផ្នត់គំនិតយេនឌ័រ<br>  ○ ការវិភាគយេនឌ័រ | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម |

| | | |
|---|---|---|
| | ○ ការលើសអើងទាក់ទង និងយេនឌ័រ | |
| **សប្តាហ៍ទី៣** | • ការចុះឈ្មោះអ្នកចូលរួម<br>• ការវិភាគតួនាទីយេនឌ័រក្នុងរបរកសិកម្ម<br>• យេនឌ័រ និងអំណាច<br>• ការផ្តល់ភាពអង់អាចដល់ស្ត្រី | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម |
| **សប្តាហ៍ទី៤** | • ការចុះឈ្មោះអ្នកចូលរួម<br>• ផលិតកម្មដំណាំដំណាំស្រូវឬបន្លែ៖ ការជ្រើសរើសពូជ និងរៀបចំថ្នាលសំណាប ឬពូជបន្លែ<br>• មេរៀនពិសេស៖ កត្តាចង្រៃនិងវិធានការណ៍កម្ចាត់លើថ្នាលសំណាបឬថ្នាលកូនបន្លែ<br>• ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម |
| **សប្តាហ៍ទី៥** | • រំលឹកមេរៀនសប្តាហ៍មុន<br>• ការចុះពិនិត្យស្រែបង្ហាញដំណាំ សត្វ តាមក្រុម<br>• មេរៀនចំបង៖ ការជ្រើសរើស និងការគ្រប់គ្រងពូជសត្វ (មាន់ឬជ្រូក) មកចិញ្ចឹម<br>• ល្បែងកំសាន្ត និងល្បែងស្ថាបនាក្រុម<br>• ការរៀបចំទ្រុង និងរោងឬរបងព័ទ្ធជុំវិញ ចិញ្ចឹមមាន់<br>• ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម |
| **សប្តាហ៍ទី៦** | • រំលឹកមេរៀនសប្តាហ៍មុន<br>• ការចុះពិនិត្យស្រែបង្ហាញដំណាំ និងសត្វ តាមក្រុម<br>• មេរៀនចំបងៈ បច្ចេកទេសដាំដុះដំណាំ (ស្រូវ ឬបន្លែ)៖រៀបចំដី ការដាំកូន.....<br>• ល្បែងកំសាន្ត និងល្បែងស្ថាបនាក្រុម<br>• មេរៀនពិសេសៈ ការគ្រប់គ្រង និងការកំចាត់សត្វល្អិតលើដំណាំ (ស្រូវ ឬបន្លែ)<br>• ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម |
| **សប្តាហ៍ទី៧** | • រំលឹកមេរៀនសប្តាហ៍មុន<br>• ការចុះពិនិត្យស្រែបង្ហាញដំណាំ សត្វ តាមក្រុម<br>• មេរៀនចំបងៈ ចំណី និងអាហារូបត្ថម្ភសម្រាប់សត្វ<br>• ប្រភេទចំណីសត្វ (មាន់ឬជ្រូក)<br>• ការផលិតចំណី និងផ្តល់ចំណីសត្វ<br>• ល្បែងកំសាន្ត និងល្បែងស្ថាបនាក្រុម<br>• មេរៀនពិសេស៖ គ្រប់គ្រង និងថែរក្សាចំណីសត្វ<br>• ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម |

| | | |
|---|---|---|
| **សប្តាហ៍ទី៨** | • រំលឹកមេរៀនសប្តាហ៍មុន<br>• ការចុះពិនិត្យស្រែបង្ហាញដំណាំ សត្វ តាមក្រុម<br>• មេរៀនចំបង: ការគ្រប់គ្រងទឹកក្នុងស្រែ<br>• ល្បែងកំសាន្ត និងល្បែងស្ថាបនាក្រុម<br>• មេរៀនពិសេស៖ វិធានការណ៍គ្រប់គ្រងនិងកម្ចាត់ស្មៅចង្រៃ<br>• ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម |
| **សប្តាហ៍ទី៩** | • រំលឹកមេរៀនសប្តាហ៍មុន<br>• ការចុះពិនិត្យស្រែបង្ហាញដំណាំ សត្វ តាមក្រុម<br>• មេរៀនចំបង៖ ការថែទាំសុខភាព និងអនាម័យសត្វ<br>• ជម្ងឺប៉ារាស៊ីតមាន់ និងការចាក់វ៉ាក់សាំងការពារ<br>• ល្បែងកំសាន្ត និងល្បែងស្ថាបនាក្រុម<br>• មេរៀនពិសេស៖ ការចម្លងជម្ងឺរោគសញ្ញានិងការទំលាក់ព្រូន<br>• ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម |
| **សប្តាហ៍ទី១០** | • រំលឹកមេរៀនសប្តាហ៍មុន<br>• ការចុះពិនិត្យស្រែបង្ហាញដំណាំ សត្វ តាមក្រុម<br>• មេរៀនចំបង៖ វិធានការណ៍គ្រប់គ្រង និងកំចាត់សត្វល្អិតចង្រៃ លើដំណាំៈសត្វល្អិតចំបងៗ<br>• ល្បែងកំសាន្ត និងល្បែងស្ថាបនាក្រុម<br>• មេរៀនពិសេស៖ សុវត្ថិភាពប្រើប្រាស់ថ្នាំកសិកម្ម<br>• ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម |
| **សប្តាហ៍ទី១១** | • រំលឹកមេរៀនសប្តាហ៍មុន<br>• ការចុះពិនិត្យស្រែបង្ហាញដំណាំ សត្វ តាមក្រុម<br>• មេរៀនចំបង៖ វិធានការណ៍គ្រប់គ្រង និងកំចាត់ជម្ងឺសត្វសំខាន់ៗ៖ការចំលងជម្ងឺ រោគសញ្ញា និងបង្ការការពារ<br>• ល្បែងកំសាន្ត និងល្បែងស្ថាបនាក្រុម<br>• មេរៀនពិសេស៖ វិធានការណ៍ការពារជម្ងឺឆ្លងសត្វ<br>• ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ | - ក្រុមការងារខេត្ត និងស្រុក<br>- ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>- កសិករចូលរួម |
| **សប្តាហ៍ទី១២** | • រំលឹកមេរៀនសប្តាហ៍មុន<br>• ការចុះពិនិត្យស្រែបង្ហាញដំណាំ សត្វ តាមក្រុម<br>• មេរៀនចំបង៖ វិធានការណ៍គ្រប់គ្រង និងកំចាត់សត្វល្អិតចង្រៃ លើដំណាំៈសត្វល្អិតចំបងៗ<br>• ល្បែងកំសាន្ត និងល្បែងស្ថាបនាក្រុម<br>• មេរៀនពិសេស៖ សុវត្ថិភាពប្រើប្រាស់ថ្នាំកសិកម្ម | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម |

| | | |
|---|---|---|
| | • ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ | |
| **សប្តាហ៍ទី១៣** | • រំលឹកមេរៀនសប្តាហ៍មុន<br>• ការចុះពិនិត្យស្រែបង្ហាញដំណាំ សត្វ តាមក្រុម<br>• មេរៀនចំបង៖ ការគ្រប់គ្រងជីជាតិដី និងសារធាតុចិញ្ចឹម សម្រាប់ដំណាំ(ស្រូវ ឬបន្លែ)<br>• ល្បែងកំសាន្ត និងល្បែងស្ថាបនាក្រុម<br>• មេរៀនពិសេស៖ ការបាចជីបំប៉នលស់ដំណាំស្រូវ ឬបន្លែ<br>• ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម |
| **សប្តាហ៍ទី១៤** | • រំលឹកមេរៀនសប្តាហ៍មុន<br>• ការចុះពិនិត្យស្រែបង្ហាញដំណាំ សត្វ តាមក្រុម<br>• មេរៀនចំបង៖ វិធានការណ៍គ្រប់គ្រង និងកំចាត់ជម្ងឺសត្វ (ត)សំខាន់ៗ៖ការចម្លងជម្ងឺ រោគសញ្ញា និងបង្ការការពារ<br>• ល្បែងកំសាន្ត និងល្បែងស្ថាបនាក្រុម<br>• មេរៀនពិសេស៖ វិធានការណ៍ការពារជម្ងឺឆ្លងសត្វ(ត)<br>• ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម |
| **សប្តាហ៍ទី១៥** | • រំលឹកមេរៀនសប្តាហ៍មុន<br>• ការចុះពិនិត្យស្រែបង្ហាញដំណាំ សត្វ តាមក្រុម<br>• **មេរៀនចំបង:** បច្ចេកទេសក្រោយពេលប្រមូលផល ដំណាំស្រូវ<br>• ការប្រមូលសម្រាប់គ្រាប់ពូជ និងគ្រាប់ស្រូវល្អ<br>• ការបោកបែន<br>• ហាល និងរក្សាទុកដាក់គ្រាប់ស្រូវ<br>• ល្បែងកំសាន្ត និងល្បែងស្ថាបនាក្រុម<br>• **មេរៀនពិសេស:** ការគ្រប់គ្រង និងវិធានការណ៍កំចាត់សត្វ ក្នុងឃ្លាំងស្តុកផលិតផល<br>• ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម |
| **សប្តាហ៍ទី១៦** | • រំលឹកមេរៀនសប្តាហ៍មុន<br>• ការចុះពិនិត្យស្រែបង្ហាញដំណាំ សត្វ តាមក្រុម<br>• មេរៀនចំបង៖ វិធានការណ៍គ្រប់គ្រង និងកំចាត់ជម្ងឺសត្វសំខាន់ៗ៖ការចំលងជម្ងឺ រោគសញ្ញា និងបង្កាការពារ<br>• ល្បែងកំសាន្ត និងល្បែងស្ថាបនាក្រុម<br>• មេរៀនពិសេស៖ ជីវសុវត្ថិភាពសត្វ<br>• ការគ្រប់គ្រងអាជីវកម្ម | - ក្រុមការងារខេត្ត និងស្រុក<br>- ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>- កសិករចូលរួម |

| | | |
|---|---|---|
| | • ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ | |
| **សប្តាហ៍ទី១៧** | • រំលឹកមេរៀនសប្តាហ៍មុន<br>• ការចុះពិនិត្យស្រែបង្ហាញដំណាំ សត្វ តាមក្រុម<br>• មេរៀនចំបងៈ វិភាគសេដ្ឋកិច្ចស្រែបង្ហាញគំរូ ដំណាំ សត្វ ឬ របរអាជីវកម្មកសិកម្ម<br>• ការយល់ដឹងអំពីដំណើរការទីផ្សារ និងទីផ្សារ<br>• ល្បែងកំសាន្ត និងល្បែងស្ថាបនាក្រុម<br>• រៀបចំផែនការទិវាបង្ហាញ និងបិទវគ្គ | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម |
| **សប្តាហ៍ទី១៨** | • រំលឹកមេរៀនសប្តាហ៍មុន<br>• ការចុះពិនិត្យស្រែបង្ហាញដំណាំ សត្វ តាមក្រុម<br>• មេរៀនចំបងៈ ប្រលងបញ្ចប់វគ្គសាលារៀនស្រែកសិករ<br>• សម្រាក<br>• ការរៀបចំផែនការបិទសាលារៀនស្រែកសិករ<br>• ការលើកផែនការសម្រាប់សប្តាហ៍ក្រោយ<br>• ទិវាស្រែ<br>• របាយការណ៍បូកសរុបសាលារៀនស្រែកសិករ<br>• ពិធីបិទវគ្គសាលារៀនស្រែកសិករ។ | • ក្រុមការងារខេត្ត និងស្រុក<br>• ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម<br>• កសិករចូលរួម<br>• រដ្ឋអំណាចមូលដ្ឋាន<br>• តំណាងក្រសួងកសិកម្ម |

**<u>កំណត់សំគាល់ៈ</u>** គ្រប់ប្រធានបទមេរៀន និងមេរៀនពិសេសតាមសប្តាហ៍នីមួយៗនៃសាលារៀនស្រែកសិករ អាចមានការផ្លាស់ប្តូរទៅតាមបញ្ហាដែលនឹងកើតមានឡើងនៅពេលចុះពិនិត្យជាក់ស្តែងក្នុងស្រែបង្ហាញ និងតាមតម្រូវការចាំបាច់របស់កសិករ។

## ឃ. ការណែនាំការរៀបចំ និងប្រើប្រាស់ប្រអប់សំណួរ

ការប្រើប្រអប់សំណួរ គឺជាការសាកល្បង ឬ ប្រឡង នៅលើទីវាលជាក់ស្តែងផ្ទាល់ដោយមិនប្រើប្រាស់ក្រដាស និងប៊ិចឡើយ។ ការរៀបចំបង្កើតប្រអប់សំណួរវាមានលក្ខខណ្ឌមួយដែលសំណួរត្រូវទាក់ទងនឹងស្ថានភាពកើតមានឡើងនៅក្នុងស្រែ ឬភូមិ។ សំណួរដែលបង្កើតឡើងនេះ គឺជាប្រភេទសំណួរដែលអាចឆ្លើយបាននៅពេលបន្ទាប់ពីសិក្ខាកាមសង្កេតមើលនៅកន្លែងឬស្រែហើយ។ បើសិនគ្មានសំណាកជាក់ស្តែង ត្រូវប្រើមធ្យោបាយត្រួតពិនិត្យ សាមញ្ញមួយដែលអាចឱ្យសិក្ខាកាមព្យាយាមឆ្លើយបាននៅកន្លែងដែលគ្មានទីស្រែមើលឃើញជាក់ស្តែង ហើយបើសិនជាចាំបាច់ ត្រូវការរៀបចំចម្លើយជាស្រេចសម្រាប់ឱ្យសិក្ខាកាមជ្រើសរើស។ ប្រអប់សំណួរត្រូវរៀបចំចម្លើយជា លក្ខណៈជ្រើសរើសដូចជា ចំលើយ ក ខ ឬគ ។ សំណួរគប្បីប្រើជាគ្រាមភាសារបស់កសិករ ទៅតាមស្រុកនីមួយៗ និងរៀបចំឱ្យមានលក្ខណៈសាមញ្ញងាយយល់បានគ្រប់ៗគ្នា ។

ស្ថានភាពនៅក្នុងស្រែ សំណួរត្រូវទាក់ទងទៅនឹងបញ្ហាអាចមើលឃើញ ពីកន្លែងដែលដាក់សំណួរ។ ការរៀបចំសំណួរ គប្បីមានទំនាក់ទំនងទៅនឹងស្ថានភាពពាក់ព័ន្ធនៅក្នុងស្រែ ឬទីកន្លែងដូចជា ប្រឡាយទឹកនេះ ចំការនេះ ស្រែនេះ សត្វនេះ សំណាកនេះ....។ល។ ឬ សំណួរត្រូវជាប់ទាក់ទងទៅនឹងសំណាក និងសភាពការណ៍កើតជាក់ ស្ដែង ។ល។

នៅក្នុងប្រអប់សំណួរអាចស្វែងរកបញ្ហា ដែលមើលឃើញជាក់ស្ដែងស្វែងរកមូលហេតុ និងលើកជាដំណោះស្រាយ។ ក្នុងសំណួរនេះយ៉ាងហោចណាស់មានចម្លើយមួយត្រឹមត្រូវដែលទាក់ទងយ៉ាងច្បាស់ជាក់លាក់ទៅនឹងសំណួរ នេះ ។

ការអនុវត្តប្រអប់សំណួរដោយព្យួរក្រដាស់ប្រអប់សំណួរទៅលើបង្គោលឬស្សី ឬ ឈើ ដោយយកទៅដោតនៅក្នុង ស្រែ ឬកន្លែងដែលកើតមានបញ្ហា។ រៀបចំតាមក្រុមនីមួយៗដោយផ្តល់ក្រដាសមានបង់លេខសំគាល់សិក្ខាកាមម្នាក់ ៗ ទៅតាមចំនួនប្រអប់សំណួរ ដើម្បីដាក់ចូលក្នុងប្រអប់ចម្លើយ។

## ការរៀបចំលំហាត់ ដោយប្រើប្រអប់សំណួរៈ

រៀបចំប្រអប់សំណួរឱ្យច្រើនទៅតាមស្ថានភាពដែលត្រូវការអាចពី២៥ ទៅ ៣០សំណួរ ដោយប្រើវិធីសាមញ្ញ ក្នុងការធ្វើប្រអប់សំណួរ យើងអាចប្រើក្រដាសស៊ីម៉ង់ត៍រឹង ។




បទស៊ីមីឡើង តាមស្នាមបន្ទាត់ដា

កាត់ស៊ីមីតាម បន្ទាត់ដាច់ៗ

ប្រើបង់ស្អិតបិទសង ខាងស៊ីមីដែលកាត់ រួចឱ្យចេញជាប្រអប់

សរសេរសំណួរ និងចំលើយ

## តារាងទី៣. គំរូវិភាគចំណូល-ចំណាយ ក្នុងកសិដ្ឋានកសិករធ្វើស្រែបន្ទាញ

### ក.ការចំណាយផលិតកម្មតាមផ្នែកនីមួយៗ

**១. ប្រភេទផលិតកម្មស្រែបន្ទាញ៖**.................................................

ថ្ងៃចាប់ផ្ដើមអនុវត្ត៖..............................................ថ្ងៃបញ្ចប់៖.........................................

| ល.រ | ឈ្មោះមុខទំនិញ និងមុខចំណាយ | ឯកតា | ចំនួនឯកតា | តម្លៃក្នុងមួយឯកតា (រៀល) | ទឹកប្រាក់សរុប (រៀល) |
|---|---|---|---|---|---|
| | មុខទំនិញ | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | ចំណាយពលកម្មសរុប | | | | |
| | **ចំណាយសរុប** | | | | |

**កំណត់ចំណាំ៖**

**១. ចំណាយមិនប្រែប្រួល៖** ប្រភេទចំណាយមូលធនវិនិយោគលើ ដី គ្រឿងចក្រ សំណង់ ឃ្លាំង ទ្រុងមាន់ ទ្រុងជ្រូក ....។ល។

**២. ចំណាយប្រែប្រួល៖** ជាប្រភេទចំណាយលើសម្ភារ និងសេវា សម្រាប់ផលិតនូវផលិតផលអ្វីមួយដូចជា ពូជ ដី ថ្នាំ វ៉ាក់សាំង ថ្នាំព្យាបាល និងពលកម្ម...។

**ខ.ចំណូលផលិតកម្មតាមផ្នែកនីមួយៗ**

**២. ប្រភេទផលិតកម្មស្រែបន្ទាញ៖**.................................................

ថ្ងៃចាប់ផ្តើមអនុវត្ត៖..............................................ថ្ងៃបញ្ចប់៖..........................................

| ល.រ | ឈ្មោះមុខចំណូល | ឯកតា | ចំនួនឯកតា | តម្លៃក្នុងមួយឯកតា(រៀល) | ទឹកប្រាក់សរុប (រៀល) |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | . | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | ចំណូលសរុប | | | | |
| | **ចំណេញ**=( **ចំណូល-ចំណាយ** ) | | | | |

## ១.៤. ការរៀបចំដំណើរការវគ្គសាលារៀនស្រែកសិករមួយ

សាលារៀនស្រែកសិករគឺជួយបង្កើនចំណេះដឹង ជំនាញ ការជឿជាក់ បណ្តុះគំនិតផ្តួចផ្តើមដល់កសិករនិង ក្នុងសហគមន៍កសិករ ព្រមទាំងធ្វើឱ្យពួកគាត់មានភាពជាម្ចាស់ និងការទទួលខុសត្រូវដោយខ្លួនគាត់។ ដំណើរការសាលារៀនស្រែកសិករ ការបង្រៀនដោយអនុវត្តផ្ទាល់ និងសិក្សានូវបច្ចេកទេសសំខាន់ៗ រៀបចំនូវស្រែសិក្សា និងទិវាស្រែ។ល។

ការរៀបចំ និងដំណើរការសាលារៀនស្រែកសិករមួយត្រូវៈ

- មានការចូលរួមពីកសិករ និងអ្នកសម្របសម្រួលកំណត់ប្រធានបទ និងមេរៀនសិក្សា
- អនុវត្តទៅតាមរយៈពេលមួយវដ្តនៃសកម្មភាពមួយ
- រៀបចំឱ្យមានការចុះពិនិត្យស្រែ និងកសិដ្ឋាន
- ធ្វើការវិភាគគ្រឿងប្រព័ន្ធបរិស្ថាន ការចុះប្រមូលទិន្នន័យពីស្រែសិក្សា
- មានការបកស្រាយបង្ហាញនូវលទ្ធផលអង្កេតដោយកសិករ
- ការពិភាក្សាតាមវិធីសាស្ត្រពិភាក្សាតាមក្រុម។

កម្មវិធី និងសកម្មភាពក្នុងសាលារៀនស្រែកសិករ និងសហគមន៍កសិករដោយផ្តោតទៅលើការអនុវត្តកសិកម្មល្អ និងបច្ចេកវិទ្យាកសិកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុដែលមានៈ

- បច្ចេកទេសផលិតកម្មដំណាំស្រូវស្រែទំនាបស្រោចស្រព និងស្រែទំនាបពឹងដោយទឹកភ្លៀង
- បច្ចេកទេសការកែលំអផលិតកម្មដំណាំបន្លែ
- បច្ចេកទេសផលិតកម្មដំណាំរួមផ្សំ
- បច្ចេកទេសផលិតកម្មដំណាំឈើហូបផ្លែ
- ការគ្រប់គ្រងដី និងសារធាតុចិញ្ចឹមតាមទីកន្លែងជាក់លាក់
- បច្ចេកទេសចិញ្ចឹមមាន់ ឬទាជាលក្ខណៈគ្រួសារ
- បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ
- បច្ចេកទេសវារីវប្បកម្ម (ត្រី អន្ទង់ កង្កែប....)
- ការរៀបចំក្រុម និងសហគមន៍កសិករ(ឧ.ក្រុមសន្សំ និងផលិតផលិតស្បៀងជាលក្ខណៈគ្រួសារនិងក្រុមកសិករធ្វើពាណិជ្ជកម្ម ឬកសិករអាជីព)។

សាលារៀនស្រែកសិករមួយត្រូវអនុវត្តជាមួយក្រុមកសិករសិក្សាចំនួនចាប់ពី២៥នាក់ យ៉ាងតិចស្ត្រី៤0% នៃកសិករចូលរួម ហើយសកម្មភាពក្នុងសាលារៀនមានៈ ការបណ្តុះបណ្តាល ការធ្វើបង្ហាញគំរូជាលក្ខណៈផលិតកម្មគំរូសម្រាប់សិក្សា និងធ្វើទិវាស្រែ។

ក្នុងសាលារៀនស្រែកសិករមួយត្រូវមានមន្ត្រីជំនាញបច្ចេកទេសយ៉ាងតិច១នាក់ និងភ្នាក់ផ្សព្វផ្សាយឃុំ ឬកសិករគ្រូ១នាក់ ដឹកនាំ និងសម្របសម្រួល។

សកម្មភាពជួបជុំកសិករក្នុងភូមិ ជាសាលារៀនស្រែកសិករៈ

- ជួបជុំកសិករពី ២៥ ទៅ ៣០ នាក់ ក្នុង១ ឬ២សប្តាហ៍ម្តង មានរយៈពេល១០ ទៅ ១៦ ដង

- អាហារសម្រន់រយៈពេល ១០ទៅ ១៦ សប្តាហ៍
- សម្ភារសិក្សា (សៀវភៅ ប៊ិច ក្រដាស ហ្វឺត....។ល។)។
- មន្ត្រីសម្របសម្រួល
- ឯកសារបច្ចេកទេស។

**ដំណើរសាលារៀនស្រែកសិករមួយមានៈ**

១. ការចុះបញ្ជីវត្តមានអ្នកចូលរួម
២. ការរំលឹកឡើងវិញនូវសកម្មភាពពីសប្តាហ៍មុន
៣. ការចុះពិនិត្យស្រែ ឬការចិញ្ចឹមសត្វបង្ហាញ
៤. ពិភាក្សា និងអនុវត្តប្រធានបទសំខាន់ (**<u>ឧទាហរណ៍</u>៖** ការប្រើប្រាស់ជីបំប៉នលើដំណាំស្រូវ)
៥. ល្បែងស្ថាបនាក្រុម ឬល្បែងកំសាន្ត
៦. ដាក់មេរៀនពិសេសឱ្យស្របតាម ហើយទាក់ទងនឹងការពិភាក្សា ប្រធានបទសំខាន់ខាងលើ
**<u>ឧទាហរណ៍</u>៖** រោគសញ្ញាកង្វះជីជាតិ
៧. ការវាយតម្លៃ និងលើកផែនការសប្តាហ៍។

**តារាងទី៦. គំរូរៀបចំកម្មវិធីសិក្សាប្រចាំសប្តាហ៍**

| ពេលវេលា | សកម្មភាព និង ប្រធានបទ | គោល បំណង | វិធីសាស្ត្រ បង្រៀន | តម្រូវ ការសម្ភារ | អ្នកទទួល ខុសត្រូវ |
|---|---|---|---|---|---|
| ០៧:៣០-០៧:៤៥ | ចុះវត្តមាន កសិករ | ចំនួនកសិករ ចូលរួម | -ចុះពិនិត្យ និង ពិភាក្សា | បញ្ជីវត្តមាន | អ្នកផ្សព្វផ្សាយស្រុក និងប្រធានក្រុម |
| ០៧:៤៥-០៨:០០ | រំលឹកមេរៀន | | | | |
| ០៨:០០-០៩:៣០ | ចុះពិនិត្យស្រែ បង្ហាញ | | | | |
| ០៩:៣០-០៩:៤៥ | សម្រាក និង ល្បែងកំសាន្ត | | | | |
| ០៩:៤៥-១១:០០ | មេរៀនពិសេស | | | | |
| ១១:០០-១១:១៥ | វាយតម្លៃវគ្គ | | | | |
| ១១:១៥-១១:៣០ | លើកផែនការ | | | | |

## ការវាយតម្លៃអាចធ្វើទៅតាមសច្ចាប់

| អ្វីដែលប្រព្រឹត្តទៅបានល្អ ☺ | អ្វីត្រូវការកែលំអ 😐☹ | សំណូមពរ និង ការណែនាំ |
|---|---|---|
| ១ | | |
| ២ | | |
| ៣ | | |
| ៤ | | |
| ។ល។ | | |

## ១.៥. បិទវគ្គ និងធ្វើទិវាស្រែ

- ប្រកាសហេតុ និង ប្រកាសគណៈអធិបតី និងអ្នកចូលរួម
- ចុះទស្សនា ពិនិត្យពិពណ៌ និងស្រែបង្ហាញ
- ធ្វើរបាយការណ៍លទ្ធផលវគ្គសាលារៀនស្រែកសិករ
- ការចែកវិញ្ញាបនប័ត្រ
- ការចាប់អារម្មណ៍របស់តំណាងកសិករ
- មតិបិទសាលារបស់គណៈអធិបតី
- ហូបបាយសាមគ្គី។

### ការធ្វើទិវាបង្ហាញឬទិវាស្រែ

ការធ្វើទិវាបង្ហាញ គឺជាសកម្មភាពផ្សព្វផ្សាយ និងបង្ហាញពីលទ្ធផលសាលារៀនស្រែកសិករ ការធ្វើបង្ហាញ ពីផលិតកម្មគំរូនូវបច្ចេកទេសដែលបានអនុវត្តក្នុងភូមិ ដើម្បីបង្ហាញដល់កសិករ និងអ្នកពាក់ព័ន្ធនានា ដែលមិនបានចូលរួម និងពង្រីកការជះឥទ្ធិពលបច្ចេកទេសដល់កសិករជិតខាងនៅក្នុងភូមិ និងតំបន់ និងការផ្សព្វផ្សាយនូវផលិតផលដែលផលិតបាន។

**ការធ្វើទស្សនកិច្ចសិក្សា**

ក្នុងពិធីបិទវគ្គ យើងអាចរៀបចំជាកទស្សនកិច្ចកសិករ ដែលជាសកម្មភាពសិក្សាដោយផ្លាស់ប្តូរបទពិសោធន៍ ជំនាញបច្ចេកទេសពីកន្លែង មួយទៅកន្លែងមួយ រវាងកសិករ សហគមន៍កសិករ អ្នកសម្របសម្រួល អ្នកផលិត និងអ្នកទិញ។ល។

## ១.៦. ការដំណើរការសាលារៀនស្រែកសិករដោយកសិករគំរូ

កសិករដែលបានចូលរៀនក្នុងសាលារៀនស្រែកសិករ អាចដំណើរការបណ្តុះបណ្តាលកសិករ និងសម្របសម្រួលក្នុងសាលារៀនស្រែកសិករបាននូវបច្ចេកទេស និងវិធីសាស្ត្រដែលគាត់បានសិក្សាពីសាលារៀនស្រែកសិករ ដល់កសិករផ្សេងទៀត។

## ១.៧. ការតាមដានបន្តរបស់អ្នកសម្របសម្រួល

បន្ទាប់ពីបញ្ចប់វគ្គសាលារៀនស្រែកសិករ អ្នកសម្របសម្រួលត្រូវធ្វើការចុះតាមដានបន្តនិងណែនាំបច្ចេកទេសដល់កសិករជាប្រចាំជារៀងរាល់ខែ។

# ជំពូកទី ៣
# គោលគំនិត វិធីសាស្ត្រ និងឧបករណ៍សំខាន់ៗប្រើប្រាស់ និងវិធីសាស្ត្រសម្របសម្រួល ក្នុងសាលារៀនស្រែកសិករ

6

## ១. គោលគំនិត វិធីសាស្ត្រ និងឧបករណ៍សំខាន់ៗប្រើប្រាស់ ក្នុងសាលារៀនស្រែកសិករ

### ១.១. ប្រព័ន្ធអេកូឡូស៊ី (ប្រព័ន្ធបរិស្ថាន)

ប្រព័ន្ធអេកូឡូស៊ីជាទំនាក់ទំនងវត្ថុធាតុមានជីវិត និងគ្មានជីវិតដែលមាននៅទីកន្លែងមួយ និងក្នុងបរិស្ថាន ដែលវារស់នៅ (**ឧទាហរណ៍**៖ នៅក្នុងស្រែ និងចំការ)។

**គោលបំណងនៃការសិក្សានេះគឺ៖**

- ដើម្បីបង្កើនជំនាញសម្របសម្រួលក្នុងការសិក្សាដោយរុករកស្រាវជ្រាវក្នុងសាលារៀនស្រែកសិករ
- ដើម្បីណែនាំកសិករឱ្យចេះវិភាគនិងធ្វើការសម្រេចចិត្តបានត្រឹមត្រូវលើបញ្ហាក្នុងស្រែរបស់គាត់។

**សមាសធាតុប្រព័ន្ធអេកូឡូស៊ីមួយមាន៖**

- វត្ថុធាតុមានជីវិត (ឧទាហរណ៍៖ មានស្រូវ សត្វមានប្រយោជន៍ មនុស្ស សត្វ ស្មៅ...។ល។)
- វត្ថុធាតុគ្មានជីវិត (ដី ភ្លឺ អាគារ ទឹក)
- បរិស្ថានរូបសាស្ត្រ (ពន្លឺថ្ងៃ ខ្យល់ សំណើម...។ល។)

#### ១.១.១. សកម្មភាពនៅក្នុងស្រែ ចំការ

សកម្មភាពនេះយើងត្រូវធ្វើការអនុវត្តដោយកំណត់មុខងារសរីរាង្គដែលមាននៅក្នុងប្រព័ន្ធអេកូឡូស៊ី និងពីអន្តរអំពើរបស់វាជាមួយវត្ថុធាតុ ឬសរីរាង្គផ្សេងទៀត ។

**គោលបំណងនៃការសិក្សា**

- ដើម្បីបង្កើនការយល់ដឹងពីទំនាក់ទំនងដែលមានរវាងវត្ថុមានជីវិត និងវត្ថុគ្មានជីវិតក្នុងបរិស្ថានជុំវិញរបស់យើង

- ដើម្បីឱ្យយល់ច្បាស់ពីវត្ថុមួយក្នុងបណ្តាញទំនាក់ទំនងនេះមានអន្តរអំពើបានផ្លាស់ប្តូរ ដែលវាអាចមានឥទ្ធិពលលើគ្រប់សមាសភាពទាំងអស់ក្នុងប្រព័ន្ធអេកូឡូស៊ី
- ឱ្យយល់ដឹងកាន់តែច្បាស់ពីវត្ថុធាតុ និងអន្តរអំពើដែលកើតមានឡើងក្នុងប្រព័ន្ធអេកូឡូស៊ី នៃស្រែ ឬកសិដ្ឋានរបស់យើង (ប្រព័ន្ធក្សេត្រ-បរិស្ថាន)
- ចាប់ផ្តើមប្រើប្រាស់ការយល់ដឹង និងសង្កេតរបស់យើងនៃប្រព័ន្ធក្សេត្រ-បរិស្ថាន ជាមូលដ្ឋានគ្រឹះ ដើម្បីធ្វើការសម្រេចចិត្តអំពីការគ្រប់គ្រងដំណាំ សត្វ និងបញ្ហាផ្សេងៗ ។

**៣.១.២. ជំហានអនុវត្ត**

១. ចុះទៅក្នុងស្រែ ឬកសិដ្ឋាន ដោយយកជាមួយនូវសៀវភៅកត់ត្រា ប៊ិច ដោយបែងចែកជាក្រុមតូចៗដើម្បីៈ
  - មើលវត្ថុអ្វីដែលមាននៅជុំវិញយើង នៅឆ្ងាយពីភ្នែក និងនៅជិតភ្នែកដែលយើងអាចឃើញ
  - កត់ត្រារាល់វត្ថុមានជីវិត និងវត្ថុគ្មានជីវិតដែលយើងមើលឃើញ
  - ពិភាក្សាតើវាមានទំនាក់ទំនងទៅវិញទៅមក ឬឥទ្ធិពលរបស់វាលើសមាសភាពនានា

២. ក្រោយពេលសង្កេត ២០នាទី ពិភាក្សា និងធ្វើការកត់ត្រាចូលក្នុងរបាយការណ៍ដើម្បីបង្ហាញ

៣. គ្រប់ក្រុមទាំងអស់ត្រូវគូររូបបង្ហាញនូវវត្ថុដែលយើងសង្កេតឃើញ និងគូរខ្សែបង្ហាញនូវទំនាក់ទំនងរបស់វាទៅវិញទៅមក ឬឥទ្ធិពលរបស់វាទៅវិញទៅមក

៤. បកស្រាយនិងពន្យល់ដល់សិក្ខាកាមទាំងអស់ពីអ្វីដែលយើងបានគូរនេះនិងធ្វើសេចក្តីសន្និដ្ឋាននិងការសម្រេចចិត្ត ។

**១. ២. ទស្សនៈនេះជាអ្វី? នោះជាអ្វី?**

**ក. សិក្សាពីការឆ្លើយសំណួរ ដោយសំណួរ**

**និយមន័យៈ** វាជាការសិក្សាដោយស្រាវជ្រាវរុករកអ្វីដែលកើតមានឡើងនៅក្នុង ដោយប្រើសំណួរជាចម្លើយវិញ។ វាដឹកនាំកសិករ ឬអ្នកសិក្សាឱ្យឆ្លើយសំណួរដោយសួរសំណួរៈ

- វាជម្រុញឱ្យមានការសិក្សាដោយស្រាវជ្រាវរុករក និងដឹកនាំកសិករឱ្យចេះធ្វើការវិភាគដោយខ្លួនគាត់
- វាផ្តល់ការណែនាំដល់កសិករដើម្បីវិភាគបញ្ហាសំខាន់ៗធ្វើការសម្រេចចិត្តល្អនៅលើស្រែ ឬកសិដ្ឋានរបស់គាត់

## <u>ឧទាហរណ៍</u>៖ លទ្ធផលដែលទទួលបានមកពីការសង្កេតក្នុងស្រែមួយ

| វត្ថុមានជីវិត | វត្ថុគ្មានជីវិត |
|---|---|
| -ស្មៅ ដំណាំ និងដើមឈើ (ស្រូវ ពោត បន្លែ ស្វាយ ដូង សត្វល្អិត (កណ្តូប ដង្កូវ ពីងពាង ស្រមោច) សត្វស្លាប ជន្លេន មនុស្ស គោ...។ល។ | - ដី, ព្រះអាទិត្យ, ខ្យល់ ចំការ<br>- អាគារ<br>-។ល។ |

**អន្តរអំពើ**




គោលដៅសិក្សាផ្អែកដោយការស្រាវជ្រាវរុករក គឺផ្តល់ឱកាសច្រើនសម្រាប់អ្នកសិក្សា។ វិធីសាស្ត្រសិក្សានេះ មានសារៈសំខាន់ណាស់សម្រាប់ទទួលបាននូវគោលដៅអប់រំ។ វិធីសំខាន់មួយ គឺសួរសំណួរដែលអាចឱ្យសិក្ខាកាម បង្កើតការវិភាគដោយខ្លួនឯង និងយល់ច្បាស់។ យើងបំផ្លាញការសិក្សាបើសិនយើងឆ្លើយសំណួរដោយផ្ទាល់។ សួរ សំណួរដឹកនាំសិក្ខាកាមឱ្យឆ្លើយដោយសួរសំណួរ។

មានមធ្យោបាយច្រើនក្នុងការឆ្លើយនូវសំណួរដូចជា នេះជាអ្វី? សំខាន់សម្រាប់យើងពីធម្មជាតិ គឺផ្តល់ឈ្មោះ វត្ថុនោះដែលជាទូទៅឈ្មោះជាភាសាបច្ចេកទេស ឬភាសាបរទេស។ សំណួរដែលជាទូទៅឆ្លើយដោយនិយាយថា អូ នេះជា... ? ដោយលទ្ធផលចម្លើយនេះគឺបានធ្វើឱ្យបញ្ឈប់ដល់ការសិក្សា ។

ជាមធ្យោបាយល្អគឺត្រូវឆ្លើយសំណួរបើកសិករសួរ **នេះជាអ្វី?** ត្រូវសួរទៅវិញថា៖

- **តើអ្នករកវាឃើញនៅកន្លែងណា?**
- **តើវាធ្វើអ្វី?**
- **តើវាមានច្រើនទេ?**
- **តើអ្នកធ្លាប់ឃើញវាពីមុនទេ?**
- **តោះយើងទៅមើលវាជាមួយគ្នា។**

គំនិតនេះគឺជម្រុញការសិក្សាដោយស្រាវជ្រាវរុករកនិងដឹកនាំឱ្យសិក្ខាកាម ឬកសិករនូវគំនិតវិភាគដោយខ្លួនគាត់ ។

## សកម្មភាពអនុវត្តនៅក្នុងស្រែ

## គោលបំណងសិក្សា

- សម្របសម្រួលការសិក្សាដោយស្រាវជ្រាវរុករកក្នុងចំណោមកសិករក្នុងសាលារៀនស្រែកសិករ
- ដឹកនាំកសិករឱ្យចេះវិភាគ និងធ្វើការសម្រេចចិត្តបានត្រឹមត្រូវ ។

**សម្ភារះ** ស្រែ កសិដ្ឋាន ថង់ សៀវភៅកត់ត្រា។

## ជំហានអនុវត្ត

១. ចុះទៅក្នុងស្រែ ឬ កសិដ្ឋានជាក្រុមតូចៗ

២. ក្នុងក្រុមនិមួយៗត្រូវមានតួនាទីដូចខាងក្រោម៖

- កសិករគប្បីចាប់យកសំណាកដែលមានក្នុងប្រព័ន្ធបរិស្ថានដំណាំ (សត្វចង្រៃ សត្វមានប្រយោជន៍ ស្មៅ និងវត្ថុផ្សេងៗ) ដោយសួរ **នេះជាអ្វី?តើអ្នករកវាឃើញនៅកន្លែងណា? តើវាធ្វើអ្វី? តើវាមានច្រើន ទេ? តើអ្នកធ្លាប់ឃើញវាពីមុនទេ? តើអ្នកយល់ដូចម្តេចអំពីវា?**
- ប្រសិនបើសំណួរជាសំណួរដែលត្រូវឆ្លើយជាបច្ចេកទេស គប្បីកុំទាន់ឆ្លើយ ទុកឱ្យគាត់ធ្វើការវិភាគរុករកស្រាវជ្រាវសិន
- មិនត្រូវផ្តល់ចម្លើយជាឈ្មោះទេ ដែលវាសំលាប់នូវសំណួរ និងការផ្លាស់ប្តូរប្រធានបទសម្រាប់សិក្សា

៣. បន្ទាប់មកក្រុមនីមួយៗ ធ្វើរបាយណ៍ពីដំណើរការសិក្សានេះដល់ក្រុមធំ។

# ១. ៣. ការវិភាគកេ្សត្រ-បរិស្ថាន

## និយមន័យ

ការវិភាគប្រពន្ធ័ក្សេត្រ-បរិស្ថាន បង្កើតឡើងសម្រាប់សង្កេតនូវអន្តរអំពើរវាងដំណាំ/សត្វ និងកត្តាមានជីវិត និងគ្មានជីវិតដែលមាននៅក្នុងស្រែចំការ។

ការវិភាគប្រពន្ធ័ក្សេត្រ-បរិស្ថាន ចូលរួមការសង្កេតលើដំណាំ ឬសត្វជាប្រចាំ ។ ការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាជាមធ្យោបាយមួយ រៀបចំឡើងសម្រាប់ប្រើជាឧបករណ៍សំខាន់មួយ សម្រាប់ធ្វើការសម្រេចចិត្ត ដោយផ្អែកលើកត្តាជាច្រើន។ ដំណើរនេះជំរុញឱ្យមានសិក្សាដោយស្រាវជ្រាវ និងធ្វើការវិភាគដោយខ្លួនឯង និងណែនាំ កសិករដើម្បីវិភាគ និងធ្វើការសម្រេចចិត្តដោយខ្លួនគាត់នៅលើស្រែ ឬកសិដ្ឋានរបស់គាត់។

### ហេតុអ្វីធ្វើការវិភាគប្រពន្ធ័ក្សេត្រ-បរិស្ថាន?

- បង្កើនជំនាញសម្រេចចិត្តតាមរយៈការវិភាគស្ថានភាពស្រែ ឬកសិដ្ឋាន តាមការសង្កេត គូរ និងពិភាក្សា
- បង្កើនការសម្រេចចិត្តដោយការបកស្រាយតាមក្រុមតូច និងក្រុមធំ។

## គំរូប្រមូលទិន្នន័យនៃ ការវិភាគប្រពន្ធ័ក្សេត្រ-បរិស្ថាន ដំណាំ

**ឈ្មោះសាលារៀនស្រែកសិករ៖ ...........................................** **ក្រុមទី៖ .........................................**
**វិភាគប្រពន្ធ័ក្សេត្រ-បរិស្ថានទី៖ ...........................................** **សប្តាហ៍ទី៖ ……………………………..**
**កូនស្រែទី៖ ..........................**

| | | |
|---|---|---|
| **ព័ត៌មានទូទៅ**<br>- ពូជ<br>- ថ្ងៃខែដាំដុះ<br>- កម្រិតប្រើជី<br>- អាយុកាលដំណាំ<br>- អាកាសធាតុ<br>- ពេលវេលាសង្កេត | | **ទិន្នន័យប្រមូល**<br>- កម្ពស់ដើម<br>- ប្រវែងស្លឹក<br>- ទំហំស្លឹក<br>- ចំនួនស្លឹកបំផ្លាញ<br>- ចំនួនផ្លែ/គួរ<br>- ចំនួនសត្វ |
| **រោគសញ្ញាបំផ្លាញដំណាំដែលបានឃើញ**<br>-សត្វ (លើដំណាំ ក្នុងដី និងក្នុងទឹក<br>-ជម្ងឺ រោគសញ្ញាកង្វះជីជាតិ | **រូបដំណាំ** | **សត្វមានប្រយោជន៍ធម្មជាតិ**<br>- សត្វលើដំណាំ<br>- សត្វក្នុងដី<br>- សត្វក្នុងទឹក |

| | | |
|---|---|---|
| **ការសង្កេត**<br>- ស្មៅ<br>-សំណើមដី<br>-ការបំផ្លាញ ជម្ងឺ សត្វមានប្រយោជន៍<br>- ស្ថានភាពសុខភាពដំណាំ (ការលូតលាស់) | | **អនុសាសន៍**<br>- សំអាតស្មៅ<br>- ជ្រួយដី<br>- បាចដី ឬស្រោចទឹក ។ល។<br>- តាមដានបន្ត |

## គំរូប្រមូលទិន្នន័យនៃ ការវិភាគក្សេត្របរិស្ថាន-សត្វ

**ឈ្មោះសាលារៀនស្រែកសិករះ** .......................................**ក្រុមទីះ** ................................

**វិភាគប្រពន្ធ័ក្សេត្រ-បរិស្ថានទីះ** .................................**សប្តាហ៍ទីះ** ................................

| | | |
|---|---|---|
| **ព័ត៌មានទូទៅ:**<br>- ពូជសត្វ<br>- ចំនួនសត្វ<br>- ថ្ងៃខែចិញ្ចឹម<br>- អាយុសត្វ<br>- ប្រភេទចំណី<br>- ថ្នាំការពារ/ព្យាបាល<br>- អាកាសធាតុ<br>- ពេលចុះពិនិត្យ | | **ព័ត៌មានត្រូវប្រមូល**<br>- ទម្ងន់សត្វនីមួយៗឬសរុប<br>- ទំហំខ្លួនសត្វ<br>- ប្រវែងខ្លួនសត្វ<br>- ចំនួនពង<br>- ចំនួនសត្វឈឺ<br>- ចំនួនពងមិនញាស់<br>- ចំនួនសត្វនៅសល់<br>- ចំនួនចំណីដែលផ្តល់ ។ល។ |
| **រូបសត្វ: ជម្ងឺ និងវត្ថុផ្សេងៗ ដែលបង្កបញ្ហា ដល់សត្វះ**<br>- ប៉ារ៉ាស៊ីត ចៃ តុកកែ អ៊ុត អង្កែ ។ល។ កណ្តុរ សត្វព្រៃផ្សេងៗ | **រូបសត្វ** | **រូបសត្វ និងវត្ថុមានប្រយោជន៍ដែលជួយ កំចាត់កត្តាចង្រៃះ** |

| | | |
|---|---|---|
| **ការសង្កេត៖**<br>- ជម្ងឺ ប៉ារ៉ាស៊ីត សត្វចង្រៃ<br>- សត្វមានប្រយោជន៍<br>- ស្ថានភាពទ្រុង<br>- ស្ថានភាពសុខភាពសត្វ | | **អនុសាសន៍**<br>- បន្ថែមចំណី<br>- លាងទឹក<br>- ចាក់វ៉ាក់សាំង ។ល។ |

# ២. វិធីសាស្ត្រសម្របសម្រួល ក្នុងសាលារៀនស្រែកសិករ

វិធីសាស្ត្រសម្រាប់អនុវត្ត សម្របសម្រួលក្នុងសាលារៀនស្រែកសិករ៖ ផ្តល់មេរៀន ធ្វើបកស្រាយបង្ហាញ ការចុះពិនិត្យ និងសង្កេតស្រែផ្ទាល់ ការពិភាក្សាតាមក្រុមតូច ការពិភាក្សាតាមក្រុមធំ ការបញ្ចេញយោបល់ជារួម សំណួរបំផុសគំនិត ការសាកសួរ និងចម្លើយ ការសន្ទនានិងជជែក ល្បែងស្ថាបនាក្រុម និងល្បែងកំសាន្ត ការសម្តែងតួរ ឬសម្តែងសកម្មភាព ការផ្តល់មេរៀនពិសេសខ្លីៗការធ្វើ ឬយកសំណាកជាក់ស្តែង ការធ្វើបង្ហាញ និងការបកស្រាយ ការអនុវត្តជាក់ស្តែង ការប្រើកាសែតវីដេអូ និងការចែកវេនទទួលខុសត្រូវតាមក្រុមជាដើម។

## ២.១. ការផ្តល់មេរៀន និងការបកស្រាយបង្ហាញ

ការរៀបចំការបង្រៀនមួយពេលខ្លះនាំមកនូវសំណួរ និងចម្លើយនៅពេលធ្វើការសន្និដ្ឋាន។ វិធីសាស្ត្រនេះពឹងផ្អែកទៅលើអ្នកសម្របសម្រួល ឬគ្រូឧទេស លើមាតិការឿង ជាងការបណ្តុះបណ្តាលបច្ចេកទេសផ្សេងៗ ហើយចាប់ផ្តើមសកម្មភាពដំបូងសម្រាប់បង្រៀនថ្មីមួយសម្រាប់ផ្តើមពេលប្រជុំ ឬពេលសិក្សា ។

### គោលបំណង

- បង្ហាញនូវប្រធានបទនិងឱ្យសិក្ខាកាមយល់ដឹងពីគោលការណ៍គ្រឹះ ដោយយោងនូវការយល់ដឹងជាក់លាក់ និងប្រធានបទដែលទាក់ទង ។

### ជំហានអនុវត្ត

១. បង្ហាញគោលបំណង ពីការណែនាំឱ្យស្គាល់ និងលទ្ធផលសង្ឃឹមទុក

២. ណែនាំប្រធានបទ (មានការអនុវត្តបច្ចេកទេសថ្មី)

៣. ជម្រុញឱ្យមានការពិភាក្សា ឱ្យសំណួរមួយចំនួនដល់សិក្ខាកាម

៤. ពិនិត្យភាពវិជ្ជមាន និងអវិជ្ជមានក្នុងការប្រើប្រាស់បច្ចេកទេសថ្មី

៥. សង្ខេបការសន្និដ្ឋានសំខាន់ពីការបកស្រាយ និងពិភាក្សា ។

### ផលប្រយោជន៍
- អាចអនុវត្តបាននូវគ្រប់ទិដ្ឋភាព ឬចំនួនសិក្ខាកាមទាំងអស់
- វាជាវិធីសាស្ត្របង្រៀនកំពុងពេញនិយម
- អ្នកសម្របសម្រួលអាចគ្រប់គ្រងពេលវេលា និងកំណត់ចំណងជើងមេរៀនបាន
- ជាវិធីសាស្ត្រល្អដើម្បីបង្កើនចំណេះដឹងសម្រាប់បង្ហាញនូវមេរៀនថ្មី និងបង្ហាញរួមដល់សិក្ខាកាម
- មិនពិបាកចាត់ចែង និងបែងចែកសិក្ខាកាមជាក្រុម
- អាចបង្រៀនបានពីរយៈចម្ងាយឆ្ងាយ
- បញ្ចូលឧបករណ៍បង្រៀនដូចជា៖ បញ្ចាំងរូបភាពមាន ស្លាយ បញ្ចាំងវីដេអូ ជាដើម។

### តើយើងអាចធ្វើដូចម្តេចឱ្យការបង្រៀនមានការចាប់អារម្មណ៍ច្រើន?
- និយាយបកស្រាយឱ្យបានខ្លីរយៈពេលពី ១៥-២០ នាទី យ៉ាងច្រើន
- បកស្រាយប្រធានបទឱ្យមានភាពច្បាស់លាស់មុនដំបូង កណ្តាល និងចុងបញ្ចប់
- រក្សាភាពសាមញ្ញ និងសង្កត់លើចំណុចគន្លឹះសំខាន់ៗនៃខ្លឹមសារមេរៀន
- បកស្រាយ និងផ្តល់ឯកសារសម្រាប់អានច្បាស់លាស់
- បកស្រាយដោយធ្វើកាយវិការដែលមានផលប្រយោជន៍ក្នុងការបង្រៀន
- ឲ្យសិក្ខាកាមសួរសំណួរ ផ្តល់យោបល់ និងធ្វើការតិះទៀន
- បង្រៀន និងបង្ហាញឯកសារដែលធ្វើការកែលំអឱ្យទាន់សម័យ ។

## ២.២. ការធ្វើបង្ហាញជាក់ស្តែង
ការធ្វើបង្ហាញជាវិធីសាស្ត្រដើម្បីបង្ហាញ និងបង្រៀនដល់សិក្ខាកាមនូវជំនាញ និងបច្ចេកទេសជាក់លាក់មួយ ហើយវាអាចប្រើបានសម្រាប់ជាគំរូតាមជំហានៗនៃសកម្មភាព។ ការធ្វើបង្ហាញជាក់ស្តែងមាន៖

### គោលបំណង
ដើម្បីបង្ហាញឱ្យសិក្ខាកាម ឬកសិករនូវឱកាសសម្រាប់សិក្សាតាមការអនុវត្តជាក់ស្តែងនូវបច្ចេកវិទ្យា និងបច្ចេកទេសថ្មី ។

### ជំហានអនុវត្ត
១. បង្ហាញប្រធានបទ ឬ មេរៀន និងគោលដៅនៃលំហាត់អនុវត្ត

២. ចែកសិក្ខាកាមជាក្រុមតូចៗមានគ្នាពី៤ ទៅ ៥នាក់

៣. អាចចុះទៅកន្លែងដែលត្រូវអនុវត្តជាក់ស្តែង

៤. ពិភាក្សា និងទៅជាមួយសិក្ខាកាមតាមជំហានខុសៗគ្នានៃសកម្មភាព

៥. បង្ហាញនូវជំហានខុសៗគ្នាដល់សិក្ខាកាម

៦. ក្រុមតូចនីមួយៗចែកជាក្រុមការងារទទួលខុសត្រូវថា តើអ្នកណាធ្វើអ្វី?

៧. សិក្ខាកាមអនុវត្ត ជំហានខុសៗគ្នានូវសកម្មភាពការងារ

៨. ពិភាក្សានិងសួរសំណួរអំពី ៖

- តើមានបទពិសោធន៍ដូចម្តេចនូវជំហាននីមួយៗនៃសកម្មភាពការងារ
- សកម្មភាពសរុប និងសារៈសំខាន់នៃសកម្មភាពសម្រាប់សិក្ខាកាម

៩. សន្និដ្ឋាន ជាមួយសិក្ខាកាមលើការអនុវត្តនោះ។

### ផលប្រយោជន៍

- ចូលរួមសិក្សាតាមការអនុវត្តជាក់ស្តែង
- ជម្រុញសិក្ខាកាមដែលជាអ្នកមិនហ៊ាននិយាយក្នុងក្រុមសម្រាប់ចូលរួមក្នុងវិធីសាស្ត្រអនុវត្តមួយ
- ធ្វើឱ្យជិតស្និទ្ធិទៅនឹងស្ថានភាពរស់នៅ។

## ២.៣. ការពិភាក្សាក្រុមតូច

ជាសកម្មភាពមួយដែលឱ្យសិក្ខាកាម ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងគំនិត ឬក៏ជាលទ្ធភាព មួយដើម្បីដោះស្រាយបញ្ហា ។ ជំនួសវិញនៃការពិភាក្សាប្រធានបទមួយនៅក្នុងក្រុមទាំងមូល ប្រធានបទច្រើនអាចត្រូវបានយកទៅពិភាក្សាដោយចែកចេញជាក្រុមតូចៗ ។ ប្រធានបទសំខាន់ គឺការផ្តល់មធ្យោបាយដល់អ្នកចូលរួម ម្នាក់ៗឱ្យចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា ។

**ជំហានអនុវត្ត**

១. ពិភាក្សាក្រុមអាចបែងចែកជាក្រុមតូចដើម្បីពិភាក្សាសំណួរ ឬបញ្ហាជាក់លាក់មួយ ឬពីរ

២. សមាជិកម្នាក់នៃក្រុមតូចនីមួយៗអាចរាយការណ៍នៃការរកឃើញទៅដល់ក្រុមទាំងមូល

៣. ក្រុមតូចៗអាចមានចំនួនពី ៤ ឬ៥នាក់

៤. អ្នកសម្របសម្រួលមើលម៉ោង និងគ្រប់គ្រងការផ្តល់មតិត្រឡប់វិញ ។

**សារៈប្រយោជន៍**

- អ្នកចូលរួមម្នាក់ៗអាចសំដែងគំនិត និងយោបល់របស់គេដែលជាការចូលរួម
- ផ្លាស់ប្តូរ និងចែករំលែកគំនិត (អន្តរអំពើ) និងបញ្ចេញបទពិសោធន៍រួមយ៉ាងទូលំទូលាយរបស់ពួកគេ
- អ្នកសម្របសម្រួលអាចស្ទង់អាកប្បកិរិយាដោយស្តាប់ការពិភាក្សាទាំងនេះ
- ការផ្លាស់ប្តូរល្បឿននៃវគ្គសិក្សា
- ការលើកទឹកចិត្តអ្នកចូលរួមដើម្បីឆ្លុះបញ្ចាំងលើអ្វីដែលពួកគេបានរៀននិងតើពួកគេអាចប្រើប្រាស់វា យ៉ាងដូចម្តេចនៅក្នុងការងាររបស់ពួកគេ
- ក្រុមអាចបញ្ចូលលាយឡំគ្នាដោយកសិករប្រភេទផ្សេងៗគ្នានៅក្នុងក្រុមនីមួយៗ
- អ្នកសម្របសម្រួលអាចរៀនសូត្រពីការពិភាក្សាក្រុមតូចនេះ ។

**<u>ចំណាំ</u>៖** ក្រុមមួយបកស្រាយពីគំនិតគេទាំងអស់និងក្រុមមួយទៀតជាអ្នកចូលរួមចំណែកផ្តល់គំនិតថ្មីដោយជៀសវាងការលើកឡើងដដែលៗ ។

## ២.៤. ការពិភាក្សាក្រុមធំ ឬពិភាក្សារួម

គោលបំណង នៃការពិភាក្សាក្រុមរួម/ការបកស្រាយ ជាការធ្វើសំយោគគំនិតនៃអ្នកចូលរួម ស្តីពីប្រធានបទថ្មី ឬព័ត៌មាន ដែលបានពិភាក្សានៅក្នុងក្រុម ។ វគ្គបណ្តុះបណ្តាលប្រើវិធីសាស្ត្រនៃការពិភាក្សាក្រុមរួម អាចចែកចេញជាក្រុមតូចៗ (សម្រាប់ជំហានទី៥នៃបែបបទដែលរៀបរាប់ខាងក្រោម) សម្រាប់ក្រុមពិភាក្សាតូច និងបន្តជាមួយក្រុមពិភាក្សារួម សម្រាប់រៀបចំសេចក្តីសន្និដ្ឋាន ។

### ជំហានអនុវត្ត

១. ណែនាំពីប្រធានបទដែលនឹងពិភាក្សា

២. សាកសួរអ្នកចូលរួមនូវសំណួរមួយចំនួនដែលបានរៀបចំរួចទាក់ទងនឹងប្រធានបទ

៣. ពិភាក្សាចម្លើយជាមួយអ្នកចូលរួម

៤. ណែនាំយ៉ាងខ្លី និងក្នុងលក្ខណៈមួយងាយស្រួលយល់នូវបច្ចេកវិទ្យាមួយថ្មី (ប្រធានបទ) / ព័ត៌មានបន្ថែម

៥. ពិភាក្សាជាមួយអ្នកចូលរួមលើផ្នែកវិជ្ជមាន និងអវិជ្ជមាននៃការប្រើបច្ចេកវិទ្យាថ្មី (ប្រធានបទ/ព័ត៌មានបន្ថែម)

៦. ផ្តល់គំនិត និងការសន្និដ្ឋានលើប្រធានបទ ។

### សារៈប្រយោជន៍

- អ្នកចូលរួមជាទូទៅមានការយល់ដឹងពីសកម្មភាពរួមគ្នា
- មិនចាំបាច់រៀបចំអ្នកចូលរួមឡើងវិញ ។

## ២.៥. ការបំផុសគំនិត

គោលបំណងគឺៈ ជាការណែនាំប្រធានបទថ្មី និងដើម្បីរកឃើញគំនិតថ្មី និងឆ្លើយតបយ៉ាងឆាប់ដោយឱ្យក្រុមរៀបរាប់ប្រធានបទ ឬគំនិតដោយរាយជាតារាងនៃលក្ខណៈ និងលក្ខខណ្ឌដែលពាក់ព័ន្ធ ។

### ជំហានអនុវត្ត

១. ក្រុមចាត់តាំងអ្នកកត់ត្រាដែលមិនចូលរួមពិភាក្សា តែគ្រាន់តែធ្វើការកត់ត្រាគំនិត

២. ក្រុមគិតបញ្ហាផ្សេងៗប្រធានបទ និងសំណួរដែលពួកគេចង់លើកឡើងពាក់ព័ន្ធទៅនឹងបញ្ហាពិសេសមួយ

៣. លើកទឹកចិត្តក្រុមឱ្យគិតពីបញ្ហាផ្សេងៗ

៤. លើកទឹកចិត្តឱ្យមានគំនិតច្រើន

៥. មានជម្រើស ២ សម្រាប់ការបំផុសគំនិតៈ

- អ្នកចូលរួមលើកឡើងពីគំនិត អ្នកសម្របសម្រួល សរសេរគំនិតនេះនៅលើផ្ទាំងក្រដាសធំ។
- **ការបញ្ចេញគំនិតដោយសេរី៖** សមាជិកក្រុមម្នាក់ៗសរសេរពីបញ្ហាផ្សេងៗ ប្រធានបទ ឬ សំណួរនៅលើក្រដាសតូចមួយ ។ ក្រដាសទាំងអស់នោះត្រូវបានផ្តល់ជាគំនិតត្រឡប់មកវិញនៅពេលដែលក្រដាសទាំងនោះត្រូវបានបិទជាប់នៅលើជញ្ជាំង ។

៦. ក្រោយសរសេររួច គំនិតទាំងអស់ត្រូវបានយកមកពិភាក្សាបន្ត និងវាយតម្លៃជាឧទាហរណ៍ កត់នៅលើតារាងនូវជម្រើសល្អបំផុតជាប្រព័ន្ធបន្តបន្ទាប់គ្នា

៧. គំនិតបានប្រមូលជាក្រុម (គំនិតដូចគ្នាត្រូវបានដកចេញ) និងវិភាគធ្វើដូច្នេះគំនិតទាំងនោះត្រូវជាក្រុម ជាជាងតែឯកឯង (ក្រុមត្រូវយល់ព្រមលើការដាក់ក្រដាសតូចៗទៅតាមសាច់រឿងនីមួយៗ ។

### សារៈប្រយោជន៍

- ទទួលបាន ឬបញ្ចេញគំនិត
- ផ្តោតអារម្មណ៍លើការបង្កើតគំនិតយ៉ាងច្រើនដែលអាចធ្វើទៅបានដោយមិនវិនិច្ឆ័យលើគំនិតទាំងនោះ
- វាយបញ្ហា ប្រធានបទ និងសំណួររួមឱ្យស៊ីជម្រៅនៅក្នុងក្រុម
- គំនិតទាំងអស់ត្រូវបានផ្តល់ការជឿ គោរពស្មើគ្នា
- អ្នកចូលរួមបានលើកទឹកចិត្តដើម្បីឱ្យគំនិតដោយសេរី ផ្តុំគំនិតទាំងនោះ និងធ្វើការកែលំអគំនិតមុនៗឱ្យបានប្រសើរ
- បំផុសគំនិតអាចបញ្ចេញឱ្យអស់ដោយផ្តោតតែលើគំនិតមួយណានោះ
- បង្កើតគំនិតជាទូទៅ ធ្វើឱ្យវគ្គពោរពេញទៅដោយសកម្មភាពរស់រវើក និងសកម្ម
- អ្នកចូលរួមមានអារម្មណ៍អង់អាចក្លាហានគ្រប់គ្រាន់ក្នុងការចូលរួម
- វគ្គបំផុសគំនិតអាចដំណើរការបានល្អនៅក្រុមធំ និងចំណាយពេលតិច ។

## ២.៦. ការចុះពិនិត្យ និងសង្កេតផ្ទាល់

គោលដៅគឺ៖ សិក្ខាកាមត្រូវបានផ្តល់លទ្ធភាពសម្រាប់រៀនតាមរយៈការចុះពិនិត្យ និងសង្កេតក្នុងភូមិ នៅក្នុងស្រែ និងកន្លែងដែលកើតមានបញ្ហា ។

### ជំហានអនុវត្ត

១. បង្ហាញប្រធានបទ និងគោលដៅសំខាន់ៗ នៃលំហាត់អនុវត្ត

២. ចុះពិនិត្យស្រែជាមួយសិក្ខាកាម៖

- សម្រេចចិត្តទីកន្លែងណា ឬ ផ្លូវណាដែលត្រូវដើរ
- សម្រេចចិត្តលើអ្វីដែលត្រូវសង្កេត

- រៀបចំការបែងចែកជាក្រុមតូចៗ
- បែងចែកសិក្ខាកាម ថាតើអ្នកណាត្រូវធ្វើបាយការណ៍លើអ្វីនៅពេលបន្ទាប់ពីបញ្ចប់ការដើរកាត់ស្រែ និងពិនិត្យស្រែ។

៣. ចាប់ផ្តើមជាមួយការដើរត្រួតពិនិត្យស្រែ

៤. ឈប់នៅនឹងកន្លែងល្អណាមួយ និងសួរសិក្ខាកាមអ្វីដែលគេសង្កេតឃើញ

៥. លើចំណុចពិភាក្សាសង្ខេបនូវអ្វីដែលគេសង្កេតឃើញ

៦. ត្រឡប់ពីដើរត្រួតពិនិត្យ និងសង្កេតស្រែ ពិនិត្យស្ថានភាពតាមភូមិ ឱ្យអ្នកត្រូវធ្វើរបាយការណ៍ រាយការណ៍អ្វីដែលគេសង្កេតឃើញដល់ក្រុមធំ

៧. ពិភាក្សា និងសង្ខេបនូវអ្វីដែលគេសង្កេតឃើញ។

### ផលប្រយោជន៍

- សិក្សាតាមអ្វីដែលសង្កេតឃើញពិត
- ផ្លាស់ប្តូរបរិយាកាសសិក្សា
- សិក្ខាកាមក្លាហានក្នុងបរិយាកាសរបស់ខ្លួន។

## ២.៧. ការលើកករណីសិក្សា

ឯកសារពិព៌ណនាមួយនូវសម្មតិកម្ម ឬស្ថានភាពពិតមួយយកមកប្រើដើម្បីវិភាគ និងពិភាក្សា។

### គោលបំណង៖

បង្ហាញនូវព័ត៌មានដោយទាក់ទងនឹងស្ថានភាពពិតជាក់ស្តែងពីការជោគជ័យរបស់កសិករណាមួយនៅក្នុងភូមិ ឬកសិករដែលចូលរួមសិក្សាក្នុងសាលារៀនស្រែកសិករ ។

### ជំហានអនុវត្ត

- ដាក់បង្ហាញនូវករណីដែលត្រូវសិក្សា
- ណែនាំធ្វើឱ្យសិក្ខាកាមមានការយល់ច្បាស់នូវករណីសិក្សានេះ
- បង្ហាញសំណួរសម្រាប់ពិភាក្សា និងបញ្ហាដែលត្រូវដោះស្រាយ
- ផ្តល់ពេលឱ្យសិក្ខាកាមដើម្បីដោះស្រាយបញ្ហា
- សិក្ខាកាមបង្ហាញនូវដំណោះស្រាយ និងចម្លើយរបស់គាត់
- ពិភាក្សាលើគ្រប់យោបល់ និងដំណោះស្រាយទាំងអស់
- ឱ្យសិក្ខាកាមពិភាក្សាអ្វីដែលគាត់បានរៀនពីការករណីសិក្សានេះ និងអ្វីដែលទាក់ទងទៅនឹងបរិយាកាសរបស់គាត់
- ធ្វើការសង្ខេបនូវការសន្និដ្ឋានសំខាន់ៗ ។

### ផលប្រយោជន៍

- ការពិភាក្សាលើបញ្ហាសំខាន់ៗក្នុងស្ថានភាពជាក់លាក់
- ផ្តល់សុវត្ថិភាពមួយ ដើម្បីបង្កើនជំនាញដោះស្រាយបញ្ហា
- មានឱកាសពិភាក្សាតាមក្រុម ដោះស្រាយបញ្ហាតាមក្រុម និងផ្លាស់ប្តូរទស្សនៈវិស័យផ្សេងៗ
- សិក្ខាកាមជ្រើសរើសបានគំនិតដែលទាក់ទងនឹងស្ថានភាពជាក់ស្តែងរបស់គាត់
- ការសិក្សាករណីនេះមិនសូវមានបញ្ហាចំពោះសិក្ខាកាម
- មានទំនាក់ទំនងទៅនឹងបទពិសោធន៍របស់សិក្ខាកាម ធ្វើឱ្យពួកគាត់មានការចូលរួម
- មានលក្ខណៈទូទៅ និងគំនិតទូលំទូលាយ
- បើកចំហសម្រាប់ពិភាក្សា ធនធាន និងសម្ភារដែលមាន
- ប្រើប្រាស់ដើម្បីទាញយកព័ត៌មានដែលទាក់ទងផ្សេងៗ
- ផ្តោតលើបទពិសោធន៍ដែលមាន
- ទទួលបាននូវព័ត៌មានច្រើន ។

## ២.៨. ការរៀបចំការសំដែងតួ ឬ សំដែងសកម្មភាព ( Role Play )

អ្នកចូលរួមប្រើបទពិសោធន៍របស់គេផ្ទាល់ ដើម្បីដើរតួក្នុងស្ថានភាពជាក់ស្តែងនៃជីវិតរស់នៅពិត។ ផ្តល់ឱកាសសម្រាប់អ្នកសម្របសម្រួល និងសិក្ខាកាមលើកឡើង និងវាយតម្លៃនូវបញ្ហាថ្មី ។

### គោលបំណង

បង្ហាញអ្នកចូលរួមជាមួយស្ថានភាពជីវិតពិតរបស់ពួកគេ ចេញពីទស្សនៈផ្សេងៗគ្នា និងធ្វើឱ្យពួកគេអាចស្វែងរកដំណោះស្រាយក្នុងលក្ខណៈផុលផុស ។

### ជំហានអនុវត្ត

១. បែងចែកតួនាទី/បង្កើតការសម្តែងតួ

២. ណែនាំអ្នកចូលរួមពីតួនាទីដែលត្រូវធ្វើ

៣. ធ្វើសកម្មភាពជាក់ស្តែង

៤. គ្រប់គ្រងពេលវេលាច្បាស់លាស់

៥. សាកសួរពីប្រតិកម្មអ្នកដើរតួ

៦. សួរមតិយោបល់អ្នកសង្កេតការណ៍

៧. សង្ខេបចំណុចសំខាន់ និងបកស្រាយ។

### សារៈប្រយោជន៍

- បង្កភាពរីករាយ
- ងាយស្រួលយល់ មានប្រយោជន៍សម្រាប់អ្នកមិនចេះអក្សរ

- អ្នកមើលឬស្តាប់ធ្វើការឆ្លុះបញ្ចាំង
- វិធីសាស្រ្តដើរតួនេះបង្កើនឱ្យអ្នកចូលរួមមានការជឿជាក់ដោយខ្លួនឯង
- ផ្តល់ឱកាសឱ្យពួកគេយល់ ឬការទទួលយកទស្សនៈរបស់មនុស្សដ៏ទៃ ឬតួនាទី និងជាទូទៅ បញ្ហប់ ដោយចម្លើយបានដោះស្រាយ និងការណែនាំ
- ការសិក្សាពីភាពស៊ាំញ៉ាំ និងជម្លោះនៃការប្រជុំជាក្រុម
- ពង្រឹងមេរៀនក្នុងតែពេលមួយគ្រានិងធ្វើឱ្យមានថាមពលល្អក្នុងការចូលរួម ។

**ចំណាំ៖** ការដើរតួបង្កឱ្យមានការរំភើបក្នុងចំណោមអ្នកចូលរួម ។ តាមរយៈការរំលឹកឡើងវិញត្រូវធ្វើតាមការដើរតួនេះ។

## ២.៩. ល្បែងស្ថាបនាក្រុម ( Team Building Exercise )

ជាការរៀបចំការងារដើម្បីបង្កើនប្រសិទ្ធិភាពការងាររបស់ក្រុម អាចទាក់ទងនឹងការកំណត់ បញ្ជាក់ គោលនយោបាយ គោលដៅ ដើម្បីពិនិត្យមើល និងកំណត់ឡើងវិញនូវនិតិវិធី និងដើម្បីស្វែងរកមធ្យោបាយសម្រាប់ជំរុញ និងបង្កើតការទំនាក់ទំនង ការសម្រេចចិត្ត ការប្រគល់ ការធ្វើផែនការការបង្វឹក ការលើកស្ទួយអភិវឌ្ឍ ការលើកទឹកចិត្ត បង្កើនទំនាក់ទំនងរវាងសមាជិកក្រុម និងពីខាងក្រៅ ។

**អនុវត្តល្បែងស្ថាបនាក្រុម គឺធ្វើសកម្មភាពអ្វីមួយតាមក្រុមដូចជា៖ សាងសង់ស្ពាន ទ្រុងសត្វ លំនៅដ្ឋាន។ល។**

__ឧទាហរណ៍__៖ ការសាងសង់ស្ពានរយៈពេល ១០-១៥ នាទី

**សម្ភារៈ** ក្រដាសសឺមី បង់ស្អិត ស្កុត និងកន្ត្រៃ

**ជំហានអនុវត្ត**

- ពន្យល់សិក្ខាកាមពីលំនាំ និងគោលបំណងនៃលំហាត់ល្បែងស្ថាបនាក្រុម
- បែងចែកសិក្ខាកាមជាក្រុមតូចៗពី ៥-៦ នាក់
- បែងចែកការងារ និងសម្ភារតាមក្រុមសម្រាប់អនុវត្តលំហាត់
- ឱ្យបកស្រាយពីលទ្ធផលការងាររបស់ក្រុមដល់ក្រុមធំ
- ពិភាក្សាក្រុមធំ ធ្វើសំយោគវាយតម្លៃដោយធ្វើសំណួរ និងការបញ្ចេញយោបល់បំផុសគំនិត។

## ២.១០. ការបង្កើតល្បែងកំសាន្ត ( Ice Breaker )

ជួយឱ្យសិក្ខាកាមទទួលបាន៖

- ការយល់ចិត្ត និងស្គាល់ចិត្តគ្នាទៅវិញទៅមក ពីអត្តចរិក តម្លៃ និងលក្ខណៈផ្ទាល់ខ្លួន
- ជួយឱ្យមនុស្សអៀន មានភាពក្លាហាន

- មានការសប្បាយរីករាយ
- មានបរិយាកាសសិក្សាល្អ។

**ជាល្បែងទោល៖** ច្រៀង និយាយរឿង ល្បែងសៀក កាយវិការ

**ល្បែងជាក្រុម៖** ដូចជាដំឡូងក្ដៅ ទេវតាថា ភ្លៀងរលឹម...។ល។

- រយៈពេល៖ ១០ នាទី

## ២.១១. ការសន្ទនា និងជជែក

ជាវិធីសាស្ត្រមួយ នៃសាលារៀនស្រែកសិកក្នុងការផ្លាស់ប្ដូរបច្ចេកទេស យោបល់ ជំនាញ និងឥរិយាបទ ហើយអាចប្រព្រឹត្តិទៅជាក្រុមតូចៗដែលមានមនុស្សពី ២ ទៅ ៣នាក់ ក្នុងការផ្លាស់ប្ដូរបច្ចេកទេស និងយោបល់ ជំនាញ បទពិសោធន៍ និងឥរិយាបទរបស់ពួកគាត់ ។

សិក្ខាកាមកត់ត្រានូវចំណុច និងគំនិតដែលឯកភាពគ្នា និងពួកគាត់លើកចំនុច ឬគំនិតឯកភាពគ្នាទៅបកស្រាយ និងរាយការណ៍ដល់ក្រុមពិភាក្សា ។

## ២.១២. សំណួរ និងចម្លើយ

មិនត្រូវឆ្លើយនូវដំណោះស្រាយបញ្ហារបស់កសិករភ្លាមៗទេ គឺត្រូវសួររកហេតុផល និងបញ្ហាទាំងនោះកើតពីពេលណាមក? ហើយជួបនៅកន្លែងណា? មានវិធីដោះស្រាយយ៉ាងដូចម្ដេចហើយ? ។ ការសួររបស់នេះជាអ្វី? យើងត្រូវឆ្លើយដោយសំណួរបញ្ជាក់រកឬសគល់នៃបញ្ហាថារបស់នេះកើតមកពីណា? បានមកយ៉ាងដូចម្ដេច? ធ្វើមកពីអ្វី?

សំណួរ និងចម្លើយ៖

- ការសិក្សាដោយស្រាវជ្រាវរុករក និងដឹកនាំសិក្ខាកាមឱ្យធ្វើការវិភាគដោយខ្លួនគាត់
- ការវិភាគបញ្ហាសំខាន់ៗ ធ្វើការសម្រេចចិត្តល្អនៅលើស្រែ ឬកសិដ្ឋានរបស់គាត់
- ជាវិធីសាស្ត្រសំខាន់អាចឱ្យសិក្ខាកាមបង្កើតការវិភាគដោយខ្លួនឯង និងយល់ច្បាស់

មានមធ្យោបាយច្រើនក្នុងការឆ្លើយនូវសំណួរ៖ ដូចជា **នេះជាអ្វី?** សំណួរជាទូទៅឆ្លើយដោយ និយាយថា **អូនេះជា... ?**

ជាមធ្យោបាយល្អគឺត្រូវឆ្លើយសំណួរដោយសួរសំណួរដូចជា៖ ***តើអ្នករកវាឃើញនៅកន្លែងណា? តើវាប្រើសម្រាប់ធ្វើអ្វី? តើវាមានច្រើនទេ? តើអ្នកធ្លាប់ឃើញវាពីមុនទេ? តោះយើងទៅមើលវាទាំងអស់គ្នា*** ។ គំនិតនេះគឺជំរុញការសិក្សា ដោយស្រាវជ្រាវ រុករក និងដឹកនាំឱ្យសិក្ខាកាមនូវគំនិតវិភាគដោយខ្លួនគាត់ ។

**សកម្មភាពអនុវត្ត**

**គោលបំណងសិក្សា៖**

- សម្របសម្រួលការសិក្សាដោយស្រាវជ្រាវរុករកក្នុងចំណោមកសិករក្នុងសាលារៀនស្រែកសិករ
- ដឹកនាំកសិករឱ្យចេះវិភាគ និងធ្វើការសម្រេចចិត្តបានត្រឹមត្រូវ ។

**សម្ភារៈ** ស្រែ កសិដ្ឋាន ថង់ សៀវភៅកត់ត្រា

**ជំហានអនុវត្តៈ**

១. ចុះទៅក្នុងស្រែ ឬ កសិដ្ឋានជាក្រុមតូចៗ

២. ក្នុងក្រុមនីមួយៗមានតួនាទីដូចខាងក្រោម៖

- កសិករគប្បីចាប់យកសំណាកដែលមានក្នុងប្រព័ន្ធបរិស្ថានដំណាំ (សត្វចង្រៃ សត្វមានប្រយោជន៍ ស្មៅ និងវត្ថុផ្សេងៗ) ដោយសួរ **នេះជាអ្វី? តើអ្នករកវាឃើញនៅកន្លែងណា? តើវាធ្វើអ្វី? តើវាមានច្រើនទេ? តើអ្នកធ្លាប់ឃើញវាពីមុនទេ? តើអ្នកយល់ដូចម្តេចអំពីវា?**
- បើសំណួរជាសំណួរដែលត្រូវឆ្លើយជាបច្ចេកទេស កុំទាន់ឆ្លើយទុកឱ្យគាត់ធ្វើការវិភាគសិន

៣. បន្ទាប់មកក្រុមនីមួយៗ ធ្វើរបាយការណ៍ពីដំណើរនេះដល់ក្រុមធំ។

- **សំណួរដែលត្រូវជៀសវាង**

១. **សំណួរមានន័យទូលំទូលាយច្រើន៖** នៅពេលដែលសួរអ្វីដែលមានន័យច្រើនជាងមួយសំណួរ ឬសំណួរវែង និងមានន័យចម្រុះច្រើនដែលធ្វើឱ្យសិក្ខាកាមមានការភ័ណ្ឌច្រឡំ ។

**ឧ<u>ទាហរណ៍</u>៖** អ្វីដែលជាការទទួលខុសត្រូវសំខាន់របស់អ្នក? តើមានអ្វីទៀតដែលអ្នកបានធ្វើហើយអ្នកបានពេញចិត្តវាដូចម្តេចខ្លះ? ។ សំណួរនេះធ្វើឱ្យសិក្ខាកាមមានការភ័ណ្ឌច្រឡំនឹងអាចឆ្លើយបានតែចំណុចចុងក្រោយប៉ុណ្ណោះ។ ដូចនេះសំណួរដែលត្រូវសួរគប្បីសួរមួយម្តងៗបន្តបន្ទាប់គ្នានៅពេលចាំបាច់ ។

២.**សំណួរមានភាពលោភលន់៖** មានលក្ខណៈទូលំទូលាយ មានភាពស្រពិចស្រពិលនាំឱ្យសិក្ខាកាមយល់មិនច្បាស់លាស់ក្នុងការឆ្លើយ លទ្ធផលចម្លើយច្រើនពេក ព្រោះមិនមានភាពជាក់លាក់គ្រប់គ្រាន់។

៣. **សំណួរនាំមុខ៖** សួរនាំមុខនូវចម្លើយសម្រាប់ឆ្លើយ ផ្អែកលើការសន្មត់ជាមុន ដូចជាអ្នកមានដី ២ហិកតាឬ? ។

- **សំណួរដែលល្អត្រូវប្រើ**

១. **សំណួរបើកចំហ៖** ជាសំណួរជំរុញឱ្យសិក្ខាកាមនិយាយ និងរក្សាទុកជាចំហនូវចម្លើយដែលចាប់ផ្តើមដោយប្រើពាក្យ **អ្វី កន្លែងណា អ្នកណា ហេតុអ្វី ដូម្តេច ពេលណា?** ឬប្រើប្រយោគក្នុងវិធីសាស្ត្រណា ។ល។ ដោយមិនអាចឆ្លើយបាទ ឬចាស់ទេ ។

<u>ឧទាហរណ៍</u>៖ អ្នកមានប្រតិកម្មយ៉ាងដូចម្ដេចដែរក្នុងការបង្កើតសហគមន៍កសិករ?។ សំណួរជំរុញការគិតឃើញ និងឥរិយាបទចំពោះមុខ មានលក្ខណៈល្អ និងមានប្រសិទ្ធិភាពក្នុងគ្រប់ស្ថានភាពសម្ភាសន៍ ។

២. **សំណួរស្ទង់មើល៖** ស្វែងឡើងនូវព័ត៌មានច្រើន <u>ឧទាហរណ៍</u>៖ ដូចជា **តើបច្ចេកទេសនេះអ្នកគិតឃើញយ៉ាងដូចម្ដេច? ចូរអ្នកពិព័ណ៌នាប្រាប់ខ្ញុំបានទេ? ហេតុអ្វីបានជាដូច្នេះ?។ ល។**
សំណួរស្ទង់មើល គប្បីប្រើដើម្បីសួរបញ្ជាក់ឱ្យយល់ច្បាស់នូវព័ត៌មានដែលមានរួចហើយ ។

៣. **សំណួរបិទ៖** ជាសំណួរមានចម្លើយ ឆ្លើយថា បាទឬ ចាស់ ឬក៏ចម្លើយ ដែលមានពាក្យមួយមាត់ ។ <u>ឧទាហរណ៍</u>៖អ្នកមានគំនិតចង់ចាត់ថ្នាក់សកម្មភាពរបស់អ្នកដែលអ្នកបានធ្វើឬទេ?

គុណវិបត្តិនៃសំណួរបិទនេះ គឺវាមិនអាចជំរុញឱ្យបានចម្លើយពេញលេញមួយ ។

## ២.១៣. ការផ្ដល់មេរៀនពិសេសខ្លីៗ

ត្រូវស្របទៅតាមប្រធានបទដែលយើងលើកយកមកពិភាក្សា និងសម្របសម្រួលនៅថ្ងៃដែលដំណើរការសាលារៀនស្រែកសិករ ត្រូវប្រើតាមក្រុមតូច ឬ ធំ ដែលភាគច្រើនជាលក្ខណៈបង្រៀននូវបច្ចេកទេសជំនាញដែលទាក់ទងបញ្ហាដែលកើតឡើងនៅពេលពិភាក្សា ។

***រយៈពេល*** ពី ៣០-៤៥នាទី តែអ្នកសម្របសម្រួលត្រូវបកស្រាយមិនឱ្យលើសពី ១៥-២០នាទី ហើយសល់ពីនោះត្រូវអនុវត្តដោយពិភាក្សាផ្លាស់ប្តូរគំនិតនិងយោបល់។

***សម្ភារ*** ក្រដាសផ្ទាំងធំ ហ្វឺត ឯកសារបច្ចេកទេសសម្រាប់បង្ហាញ។

**ចំណុចដែលអ្នកសម្របសម្រួលត្រូវចងចាំ៖**

- អ្នកប្រើមេរៀនពិសេសនៅពេលណា និងប្រើវិធីសាស្ត្រអ្វីឱ្យស្របតាមតម្រូវការរបស់សិក្ខាកាម និងស្របតាមពេលវេលាដែលមាន?
- អ្នកបានកំណត់ប្លង់មេរៀន និងវេលាសម្រាប់និយាយមិនឱ្យលើសពី ២០នាទី ?
- អ្នកបាននិយាយពន្យល់ច្បាស់លាស់ពីពេលចាប់ផ្ដើមពាក់កណ្ដាលទី និងចុងបញ្ចប់មេរៀន?
- ជាទូទៅរក្សាបាននូវចំណុចគន្លឹះងាយៗបានឬទេ ?
- សម្រាប់ការសម្របសម្រួល តើអ្នកបានផ្ដល់ឯកសារមេរៀនច្បាស់លាស់ឬទេ ?
- អ្នកដឹងទេថា ភាសាដែលអ្នកប្រើមានឥទ្ធិពលលើមេរៀនពិសេសដូម្ដេចខ្លះ?

## ២.១៤. ការប្រើឯកសារសោតទស្សន៍ ឬប្រព័ន្ធផ្សព្វផ្សាយបណ្ដាញសង្គម

ជាវិធីសាស្ត្រមួយក្នុងសាលារៀនស្រែកសិករ អាចបានដូចជាប្រធានបទ ពិសេស ការប្រើករណីសិក្សា ឬការបង្ហាញជាក់លាក់មួយពីព័ត៌មានអ្វីមួយដល់សិក្ខាកាមដើម្បីសិក្សា ពិភាក្សា និងវិភាគ ។

# ជំពូកទី ៤
# ការរៀបចំប្លង់មេរៀនក្នុងសាលារៀនស្រែកសិករមួយ
# 6

## ១. ការរៀបចំប្លង់មេរៀនសម្រាប់សាលារៀនស្រែកសិករ

សិក្សាសាលារៀនស្រែកសិករមួយ ១០ទៅ១៦ពេល អាស្រ័យលើប្រធានបទ ដែលអ្នកសម្របសម្រួលត្រូវរៀបចំប្លង់មេរៀន និងគម្រោងមេរៀនតាមសប្តាហ៍នីមួយៗឱ្យបានមុនដំណើរការសាលារៀន។ មេរៀននីមួយត្រូវដាក់បញ្ចូលទស្សនៈទាន និងគោលគំនិតកសិកម្មវៃឆ្លាត នឹងអាកាសធាតុ និងការ ធ្វើបរអាជីវកម្មកសិកម្មបែបធ្វើជំនួញ (Farm Business) ។ មន្ត្រីនិងភ្នាក់ងារផ្សព្វផ្សាយខេត្ត-ស្រុក និងអ្នកសម្របសម្រួលត្រូវរៀបចំប្លង់មេរៀនទាំងមេរៀនសំខាន់ៗ និងមេរៀនពិសេស តាមប្លង់គំរូដូច ខាងក្រោមៈ

### ក. កំណត់ត្រាឯកសារបច្ចេកទេស (ប្លង់មេរៀន)

- ឈ្មោះចំណងជើងមេរៀន
- និយមន័យឬគោលបំណងមេរៀន
- តម្រូវការសម្ភារ និងវិធីសាស្រ្ត
- ចំណុចសំខាន់ៗនៃមេរៀនត្រូវឱ្យកសិករយល់ដឹង។

### ខ. គម្រោងប្លង់មេរៀនក្នុងសាលារៀនស្រែកសិករ

- ចំណងជើងមេរៀន
- កាលបរិច្ឆេទ
- រយៈពេល
- អ្នកសម្របសម្រួល
- ទីកន្លែង
- គោលបំណងសិក្សា
- វិធីសាស្រ្ត
- សម្ភារ
- ជំហានអនុវត្ត
- សំណួរខ្លះសម្រាប់ជំនួយស្មារតីអ្នកសម្របសម្រួល។

## ២. គំរូប្លង់ការរៀបចំការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន

សម្រាប់មេរៀនបច្ចេកទេស កសិកម្មសំខាន់នីមួយៗក្នុងសាលារៀនស្រែកសិករត្រូវ ប្រើប្រាស់ អនុវត្តការវិភាគប្រព័ន្ធក្សេត្របរិស្ថាន ដែលជាមូលដ្ឋានក្នុងការសិក្សា។

ការវិភាគប្រពន្ធ័ក្សេត្រ-បរិស្ថាន សម្រាប់ធ្វើការសម្រេចចិត្តក្នុងក្រុមមួយពីការអនុវត្ត ឬគ្រប់គ្រង ស្ថានភាពអ្វីមួយ។ ការវិភាគប្រពន្ធ័ក្សេត្រ-បរិស្ថាន គឺជាការបង្កើតសម្រាប់សង្កេតនូវអន្តរអំពើរវាងដំណាំ/សត្វ និងកត្តាមានជីវិត និងគ្មានជីវិតដែលមាននៅក្នុងស្រែ ចំការ ឬកសិដ្ឋាន ។

ការវិភាគប្រពន្ធ័ក្សេត្រ-បរិស្ថាន ចូលរួមការសង្កេតលើដំណាំ ឬសត្វជាប្រចាំ ។ វាជាមធ្យោបាយមួយរៀបចំឡើងសម្រាប់អ្វី និងទីកន្លែងដែលយើងសិក្សាក្នុងដំណើរដ៏មានសារៈសំខាន់មួយសម្រាប់ធ្វើការសម្រេចចិត្តដោយ ផ្អែកលើកត្តាជាច្រើន ។

### ក. គោលបំណងវិភាគប្រពន្ធ័ក្សេត្រ-បរិស្ថាន

- ជំរុញឱ្យមានសិក្សាដោយស្រាវជ្រាវរុករក និងធ្វើការវិភាគដោយខ្លួនឯង
- ណែនាំកសិករដើម្បីវិភាគ និងធ្វើការសម្រេចចិត្តដោយខ្លួនគាត់នៅលើស្រែកសិដ្ឋានរបស់គាត់។

### ខ. ហេតុអ្វីធ្វើការវិភាគប្រពន្ធ័ក្សេត្រ-បរិស្ថាន?

- បង្កើនជំនាញសម្រេចចិត្តតាមរយៈការវិភាគស្ថានភាពស្រែ ឬកសិដ្ឋាន តាមការសង្កេត គូរូបភាព និងពិភាក្សា
- បង្កើនការសម្រេចចិត្តដោយការបកស្រាយតាមក្រុមតូច ក្រុមធំ និងពិភាក្សាផ្លាស់ប្តូរយោបល់។

### គ. គំរូធ្វើការចុះវិភាគក្សេត្រ-បរិស្ថានលើដំណាំ

### ១. គោលបំណង

- ឱ្យក្រុមកសិករចុះរុករកស្រាវជ្រាវបញ្ហាដែលកើតមានឡើងនៅក្នុងស្រែផ្ទាល់ យកសំណាក និងបញ្ហា នេះមកសិក្សា និងពិភាក្សារកដំណោះស្រាយ
- ឱ្យកសិករពិភាក្សាផ្លាស់ប្តូរយោបល់ បទពិសោធន៍គ្នា ដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើងនៅក្នុងស្រែ។

**២. រយៈពេល៖** ៤៥-៦០ នាទី

**៣. វិធីសាស្រ្ត៖** សំណួរបំផុសគំនិត ចុះពិនិត្យស្រែផ្ទាល់ ពិភាក្សាក្រុមតូច និងបកស្រាយលទ្ធផល

**៤. សម្ភារះ** ក្រដាសផ្ទាំងធំ ប៊ិចហ្វឺត ខ្មៅដៃពណ៌ សំណាកសត្វ រុក្ខជាតិ ស្មៅ និងដី ។ល។

### ៥. ជំហានអនុវត្ត

| វិធីសាស្ត្រ និងជំហាន | សកម្មភាព | ពេលវេលា |
|---|---|---|
| សំណួរបំផុសគំនិត<br>និងណែនាំកសិករ | - ណែនាំកសិករពីវិធីចុះធ្វើការវិភាគក្បេត្រ-បរិស្ថាន<br>- ណែនាំឱ្យក្រុមកសិករចែកតួនាទីគ្នាក្នុងការសង្កេត និងប្រមូលព័ត៌មានដោយបង្ហាញតារាងគំរូវិភាគប្រពន្ធ័ក្បេត្រ-បរិស្ថាន | ១៥ នាទី |
| ចុះពិនិត្យស្រែផ្ទាល់ | - បែងចែកតួនាទីគ្នាក្នុងក្រុមកសិករពីការប្រមូលព័ត៌មាន សង្កេត និងប្រមូលសំណាក និងកត់ត្រាបញ្ហា ដែលកើតមាននៅក្នុងស្រែ | ១៥ នាទី |
| ពិភាក្សាតាមក្រុមតូច | - ពិភាក្សា និងកត់ត្រាព័ត៌មានក្នុងតារាងគំរូ ការវិភាគប្រព័ន្ធក្បេត្របរិស្ថាន | ១៥-២០ នាទី |
| ការបកស្រាយ<br>និងសំណួរបំផុសគំនិត<br>(បកស្រាយរួមគ្នាជាមួយក្រុមសត្វ) | - ធ្វើរបាយការណ៍លទ្ធផលវិភាគ ការវិភាគប្រព័ន្ធក្បេត្របរិស្ថាន<br>- សួរសំណួរនេះជាអ្វី អ្នកឃើញវានៅកន្លែងណា? អ្នកដែលជួបវាពីមុនទេ វាមានច្រើនទេ? ។ល។<br>- សំយោគលទ្ធផល ការវិភាគប្រព័ន្ធក្បេត្របរិស្ថាន | ១៥ នាទី |

**កំណត់ចំណាំ ៖** ដំណើរការវិភាគប្រពន្ធ័ក្បេត្រ-បរិស្ថាននេះត្រូវធ្វើរៀងរាល់ពេល ឬ សប្តាហ៍ នៅក្នុងសាលារៀនស្រែ កសិករបន្ទាប់ពីដាំដុះ រួច។

ក្នុងរយៈដំណើរការសាលារៀនស្រែកសិករត្រូវធ្វើការវិភាគក្បេត្រ-បរិស្ថានពី ៨ ទៅ ១០ដង។

## ឧទាហរណ៍ គំរូប្រមូលទិន្នន័យនៃ ការវិភាគប្រព័ន្ធបរិស្ថាន-ដំណាំស្រូវ

ឈ្មោះសាលារៀនស្រែកសិករ: ............... ក្រុមទី ....... វិភាគប្រព័ន្ធបរិស្ថានលើកទី ..........សប្តាហ៍ទី.....
កូនស្រែទី: ............

| | | |
|---|---|---|
| **ព័ត៌មានទូទៅ**<br>- ពូជ៖ សែនពិដោរ<br>- ថ្ងៃ/ខែ/ដាំដុះ៖ ១៥ មករា ២០០៥<br>- កម្រិតប្រើជី៖ លាមកគោ ៥០គក្រ<br>- អាយុកាលដំណាំ៖ បែកគុម្ព<br>- អាកាសធាតុ៖ ថ្ងៃរះល្អ<br>- ពេលវេលាសង្កេត ៣០ កុម្ភៈ ២០១៦ | | **ទិន្នន័យប្រមូល**<br>- កម្ពស់ដើម៖ ៩៩ ស.ម<br>- ប្រវែងស្លឹក៖ ៣០ ស.ម<br>- ទំហំស្លឹក៖ ១.៩ ស.ម<br>- ចំនួនស្លឹកបំផ្លាញ៖ ៣<br>- ចំនួនផ្លែ/គួរ<br>- ចំនួនសត្វបំផ្លាញ៖ មមាចត្នោត ២ ដង្កូវ ៤ ។ល។ |
| គូររូបរោគសញ្ញាបំផ្លាញដំណាំដែលកើតមាននៅលើដំណាំ<br>រូបវត្ថុមានសត្វ (លើដំណាំ ក្នុងដី និងក្នុងទឹក<br>រូបរោគសញ្ញាជម្ងឺកង្វះជីជាតិ | **រូបដំណាំស្រូវ** | សត្វមានប្រយោជន៍ធម្មជាតិ<br>- សត្វពីងពាង២ អណ្តើកមាស ៣<br>- សត្វក្នុងដី៖ ខ្ទុតដី ២ ជន្លេន ២<br>- សត្វក្នុងទឹក៖ ស្រីងទឹក ៣ |
| **ការសង្កេត**<br>- វត្តមានស្មៅច្រើន<br>- សំណើមដី៖ មានទឹកតិច<br>- ការបំផ្លាញពីសត្វដង្កូវកាត់ស្លឹក សត្វមានប្រយោជន៍ច្រើន<br>- ស្ថានភាពសុខភាពដំណាំ មធ្យម | | **អនុសាសន៍**<br>- សំអាតស្មៅ<br>- ស្រោចទឹក<br>- បាចជីប៉ប៉ន<br>- តាមដានបន្ត |

## ៣. គំរូសកម្មភាពសាលារៀនស្រែកសិករក្នុងសប្តាហ៍នីមួយៗ

### ៣.១. សប្តាហ៍ទី១ : ការបើកវគ្គជាផ្លូវការ និងណែនាំពីសាលារៀនស្រែកសិករ

**កាលបរិច្ឆេទ៖** ព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦

**រយៈពេល៖** ៤ម៉ោង

**អ្នកសម្របសម្រួល៖** មន្ត្រីផ្សព្វផ្សាយខេត្ត និងស្រុកចូលរួមដោយអាជ្ញាធរមូលដ្ឋាននិងក្រុមការងារខេត្ត

**ទីកន្លែង៖** ភូមិត្រគៀត ឃុំចំប៉ី ស្រុកបាទី ខេត្តតាកែវ

**គោលបំណង៖**

- បើកវគ្គជាផ្លូវការដោយមានការទទួលស្គាល់ពីកសិករចូលរួមក្នុងភូមិ និងការគាំទ្រពីរដ្ឋអំណាចមូលដ្ឋាន និងអ្នកផ្សព្វផ្សាយ
- បង្ហាញពីគោលបំណងនៃសាលារៀនស្រែកសិករនិងវាស់ស្ទង់កម្រិតយល់ដឹងរបស់កសិករចូលរួម
- បង្កើតបទបញ្ជាផ្ទៃក្នុង បែងចែកក្រុមទទួលខុសត្រូវ និងរៀនសូត្រក្នុងសាលារៀនស្រែកសិករ។ល។

**វិធីសាស្ត្រ៖** រៀបចំពិធីជួបជុំ សំណួរបំផុសគំនិត ពិភាក្សាក្រុមតូច និងសំណួរសាកល្បង

**សម្ភារៈ** ក្រដាសផ្ទាំងធំ ប៊ិចហ្វឺត ក្រដាសព៌ណ ក្រដាសរ៉ាម ប៊ិច ខ្មៅដៃ ខ្មៅដៃព៌ណ សៀវភៅសរសេរ និងសម្ភារសិក្សាផ្សេងៗ ។ល។

**ជំហានអនុវត្ត**

| វិធីសាស្ត្រ និងជំហានអនុវត្ត | សកម្មភាព | ពេលវេលា |
|---|---|---|
| បើកសាលារៀនស្រែកសិករជាផ្លូវការ | -មតិរបស់អ្នកសម្របសម្រួល ពីមូលហេតុនិងគោលបំណងសាលារៀន និងកម្មវិធី<br>-មតិបើកវគ្គដោយគណៈអធិបតី | ១០ នាទី<br><br>១០ នាទី |
| សម្រាក និងល្បែងកំសាន្ត | - ល្បែងដំឡូងក្តៅ | ១៥ នាទី |
| សំណួរបំផុសគំនិត | ណែនាំឲ្យ៖<br>• ស្គាល់គ្នារវាងអ្នកសម្របសម្រួល និងកសិករ<br>• កសិករដឹងពីគោលបំណង និងសេចក្តីរំពឹងទុករបស់កសិករពីសាលារៀនស្រែកសិករ<br>- ចែកក្រដាសឱ្យកសិករ ឬសួរកសិករពីសេចក្តីរំពឹងទុករបស់គាត់<br>- សរសេរ ឬបិទចម្លើយរបស់កសិករដោយតម្រៀបតាមក្រុម<br>- សរុបចម្លើយ និងបង្ហាញពីសេចក្តីរំពឹងទុករួមរបស់កសិករ | ៣០ នាទី |

| | | |
|---|---|---|
| សំណួរបំផុសគំនិត និងពិភាក្សា ក្រុមធំ | - បោះឆ្នោតជ្រើសរើសប្រធានក្រុម អនុប្រធានក្រុម និងលេខា ឬបេឡាក្រុមកសិករ<br>- បែងចែកក្រុមទទួលខុសត្រូវ និងកំណត់តួនាទី ភារកិច្ចរបស់ក្រុមនីមួយៗក្នុងវគ្គសាលារៀនស្រែកសិករ<br>- បង្កើតបទបញ្ជាផ្ទៃក្នុងក្នុងរយៈពេលសិក្សា ដោយពិភាក្សាជាមួយកសិករចូលរួម | ១៥ នាទី<br>១៥ នាទី<br>១៥ នាទី |
| សំណួរបំផុសគំនិត និងលំហាត់ អនុវត្តជាក់ស្តែង | - ពន្យល់កសិករពីដំណើរការប្រឡងសាកល្បង<br>- ប្រឡងសាកល្បងដោយប្រើប្រអប់សំណួរ ផ្សារភ្ជាប់ទៅនឹងរូបភាពសំណាកជាក់ស្តែងដែលទាក់ទងនឹងមេរៀនក្នុងរយៈពេលសាលារៀនស្រែកសិករ | ១ម៉ោង ៤៥ នាទី |
| ពិភាក្សាក្រុមធំ | - ពិភាក្សាសកម្មភាពសម្រាប់សប្តាហ៍ក្រោយ | ១៥ នាទី |

## ៣.២. សប្តាហ៍ទី២: ទៅសប្តាហ៍បន្តបន្ទាប់

ចាប់សប្តាហ៍ទី២រហូតសប្តាហ៍មុនពេលពិធីបិទសាលារៀនស្រែកសិករជាផ្លូវការ គឺជាមេរៀនបច្ចេកទេសមាន៖ តួនាទីយេនឌ័រ និងការបង្កើនសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យកសិកម្ម ដំណាំ ចិញ្ចឹមសត្វ វារីវប្បកម្ម និងមេរៀនពាក់ព័ន្ធនឹងការគ្រប់គ្រងអាជីវកម្មកសិកម្ម (Farm Business School) និងសង្គម។ល។ នៅតាមសប្តាហ៍នីមួយៗត្រូវមានប្រធានបទមេរៀន សំខាន់ (Main Topics) និងមេរៀន ពិសេស (Special topics) ដែលទាក់ ទងនឹងប្រធានបទមេរៀនពិសេស។ គ្រប់ប្រធានបទក្នុងសាលារៀនស្រែកសិករ ត្រូវអនុវត្តការវិភាគប្រព័ន្ធក្សេត្របរិស្ថាន និងវិភាគ ការកសិកម្មបែបជំនួញដែលជាមូលដ្ឋានក្នុងសិក្សា។

## ៣.៣. សប្តាហ៍ទី ...... ការគ្រប់គ្រងអាជីវកម្មកសិកម្ម និងទីផ្សារ

ការសិក្សាពីការគ្រប់គ្រងអាជីវកម្មកសិកម្ម (Farm Business)ជាវេទិកាមួយដើម្បី៖

- ឱ្យកសិករលើយកបញ្ហាដោះស្រាយរួមគ្នា ពីបញ្ហារបរអាជីវកម្ម ទីផ្សារ និងកាលានុវត្តភាព។
- ឱ្យកសិករលើកយកគំនិតមកពិភាក្សារួមគ្នាលើរបរអាជីកម្ម សម្រាប់អភិវឌ្ឍ ឬពង្រឹងជំនាញ ឬអាជីពក្នុងផលិតនូវផលិតផលអ្វីដែលមានផលិតភាពខ្ពស់ ទទួលបានចំណេញច្រើន និងតាមតម្រូវការទីផ្សារ និងតម្រូវការដោះស្រាយ ឬអន្តរាគមន៍លើបច្ចេកទេស ទុន និងធាតុចូលនានា បញ្ហាទឹក និងទីផ្សារ។

## ១. ពិភាក្សាជាមួយកសិករពីនិន្នាការផ្លាស់ប្តូរការអនុវត្តរបរកសិកម្ម

| **ពេលវេលា** | **កសិកម្មសម្រាប់ស្បៀងអាហារ** | **កសិកម្មសម្រាប់ប្រាក់ចំណូល** | **មូលហេតុនៃការប្រែប្រួល** |
|---|---|---|---|
| ១០ ឆ្នាំមុន | (រូបប្រភេទកសិកម្ម ឧ.ស្រូវ)  | (រូបបង្ហាញចំនួនទឹកប្រាក់) | |
| ៥ឆ្នាំ មុន |  | | |
| បច្ចុប្បន្ន |  | | |

## ២. ការកំណត់ពីរបរកសិកម្ម និងអាជីវកម្មមួយ

| | | |
|---|---|---|
|  |  |  |

**ឧទាហរណ៍១.** ផលិតកម្មស្រូវ ដំណាំរួមផ្សំ ដំណាំបន្លែ ផលិតពូជដំណាំ....។ល។

**ឧទាហរណ៍២.** ផលិតកម្មសត្វ៖ ចិញ្ចឹមមាន់សាច់ ចិញ្ចឹមមាន់យកពង ចិញ្ចឹមទាយកសាច់ ចិញ្ចឹមទាយកពង ជ្រូក គោ ត្រី  ផលិតពូជសត្វ ដំណាំបន្លែ....។ល។

### ៣. ពន្យល់កសិករពីការខុសគ្នារវាងអាជីវកសិកម្ម (Farm Business) និងរបរកសិកម្មបែបសហគ្រាស (Farm Enterprise)

| របរអាជីវកម្មកសិកម្ម | របរកសិកម្មបែបសហគ្រាស |
|---|---|
